**BBI0101**

**សម្ភាសជាមួយឈ្មោះ ទុំ សឿន ភេទប្រុស អាយុ៧២ឆ្នាំ**

**មុខងារខ្មែរក្រហមៈ ប្រធានគុកភ្នំទ្រយោង**

**ស្រុកកំណើតនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ**

**សព្វថ្ងៃរស់នៅភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង**

**ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី**

**០១:៣៥:៤៣**

**៥១ទំព័រ**

ដានី ៈ បាទ! ចឹងអ៊ំជួយមានប្រសាសន៍វៀងៗតិច ពីព្រោះខ្លាចស្តាប់អត់ច្បាស់ ពេលដែលខ្ញុំយកទៅចម្លងចេញថា អត់បានល្អ ។ ខ្ញុំឈ្មោះ ដានី ហើយគាត់ឈ្មោះដារ៉ា ។ ពួកខ្ញុំទាំងពីរនាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ធ្វើការទាក់ទងនឹងការប្រមែប្រមូលការចងក្រងឯកសារ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ យើងចងក្រងឯកសារពី សម័យ៧៥ដល់៧៩នោះ គឺសម្រាប់ទុកឲ្យក្មេងៗជំនាន់ក្រោយ សម្រាប់អ្នកសិក្សាស្រាវជ្រាវដែលគេចង់អាន គេចង់ដឹងរឿងរ៉ាវនៅសម័យនឹង គេអាចទៅអានគេអាចទៅស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបាន ។ ហើយពួកខ្ញុំទាំងពីរនាក់មកជួបអ៊ំនេះ គឺចង់ដឹងរឿងរ៉ាវខ្លះទាក់ទងដូចថាអ៊ំធ្លាប់បានឆ្លងកាត់ ជីវិតធ្លាប់បានឆ្លងកាត់កាលពីសម័យ៧៥-៧៩ ។ ហើយអ៊ំអនុញ្ញាតិឲ្យពួកខ្ញុំសួរនាំទាក់ទងពីរឿងរ៉ាវពីជីវិតអ៊ំពីសម័យនឹងដែរ?

សឿន ៈ បានៗ ។

ដានី ៈ អ៊ំអត់មានចម្ងល់អី ចង់សួរនាំខ្ញុំទាក់ទងពី?

សឿន ៈ អត់ៗ ។

ដានី ៈ អត់មាន?

សឿន ៈ បាទ!

ដានី ៈ ចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ ឈ្មោះពេញអីដែរ?

សឿន ៈ ពេញ ទុំ សឿន ។

ដានី ៈ ឈ្មោះ ទុំ?

សឿន ៖ ទុំ ។

ដានី ៖ ទុំ សឿន?

សឿន ៖ បាទ!

ដានី ៖ អ៊ំអាយុប៉ុន្មានហើយ សព្វថ្ងៃ?

សឿន ៖ អាយុ៧២ ។

ដានី ៖ អាយុ៧២?

សឿន ៖ បាទ!

ដានី ៖ អ៊ំកំណើតកើតជានៅភូមិស្រុកអីដែរ?

សឿន ៖ នៅភូមិត្រពាំងជ្រៃ ។

ដានី ៖ ភូមិត្រពាំងជ្រៃ ឃុំអីដែរ?

សឿន ៖ ឃុំត្រពាំងធំខាងត្បូង ។

ដានី ៖ ឃុំត្រពាំងធំខាងត្បូង?

សឿន ៖ បាទ!

ដានី ៖ ស្រុកអី?

សឿន ៖ ត្រាំកក់?

ដានី ៖ ស្រុកត្រាំកក់?

សឿន ៖ ខេត្តតាកែវ ។

ដានី ៖ ខេត្តតាកែវ?

សឿន ៖ បាទ!

ដានី ៖ ចុះអ៊ំសព្វថ្ងៃរស់នៅក្នុងភូមិឃុំស្រុកអីដែរ សព្វថ្ងៃនេះ?

សឿន ៖ ដែលនៅក្នុងភូមិគីឡូ១៣ ។

ដានី ៖ ភូមិគីឡូ១៣?

សឿន ៖ បាទ! ឃុំសន្តិភាព ។

ដានី ៖ សន្តិភាព ស្រុក?

សឿន ៖ ស្រុកសំពៅលូន ។

ដានី ៖ សំពៅលូន ខេត្តៗបាត់ដំបង?

សឿន ៖ បាទ!

ដានី ៖ ចុះអ៊ំប្រពន្ធអ៊ំ គាត់ឈ្មោះអីដែរ?

សឿន : គ្រួសារឈ្មោះ ជូ និន ។

ដានី : ឈ្មោះ ជូ?

សឿន : បាទ!

ដានី : ជូ និន ។ គាត់សព្វថ្ងៃអាយុប៉ុន្មានដែរ?

សឿន : អាយុ៦៥ ។

ដានី : អាយុ៦៥ឆ្នាំ ។ ចុះអ៊ំស្រី គាត់ស្រុកកំណើតកើតជាគាត់នៅណាដែរ?

សឿន : នៅជាមួយគ្នា ។

ដានី : នៅភូមិ?

សឿន : ភូមិជុំគ្នា ។

ដានី : នៅភូមិស្រុកជាមួយអ៊ំដែរ?

សឿន : បាទ!

ដានី : ស្រុកកំណើត?

សឿន : បាទ!

ដានី : អ៊ំសព្វថ្ងៃ មានកូនចៅប៉ុន្មាននាក់ហើយ?

សឿន : កូន៩នាក់ ។

ដានី : កូន៩នាក់?

សឿន : បាទ!

ដានី : ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សឿន : ស្រី៥ ប្រុស៤ ។

ដានី : ស្រី៥ ប្រុស៤ ។ អ៊ំសព្វថ្ងៃ អ៊ំមុខរបររកស៊ីអ៊ំធ្វើអីទៅ?

សឿន : ខ្ញុំធ្វើចំការ ។

ដានី : អ៊ំធ្វើចំការៗ ធ្វើអីទៀត?

សឿន : អត់មានធ្វើអី ។

ដានី : ធ្វើចំការអីខ្លះទៅ?

សឿន : ចំការដាំសណ្តែក ដាំដំឡូង ដាំពោត ។

ដានី : សណ្តែក ដំឡូង ពោត?

សឿន : បាទ!

ដានី : ចុះអ៊ំឪពុកអ៊ំគាត់ឈ្មោះអីដែរ ឪពុកអ៊ំបង្កើត?

សឿន ៖ ឪពុក សោគ ទុំ ។

ដានី ៖ បាទ?

សឿន ៖ សោគ ទុំ ។

ដានី ៖ សោគ ទុំ ។ សព្វថ្ងៃ គាត់នៅរស់ ឬខូចហើយ?

សឿន ៖ គាត់ស្លាប់បាត់ហើយ ។

ដានី ៖ គាត់ស្លាប់បាត់ហើយ ស្លាប់តាំងពីអង្កាល់ទៅអ៊ំ?

សឿន ៖ តាំងពីឆ្នាំ៧១ ។

ដានី ៖ ៧១? ចុះម្តាយ?

សឿន ៖ ម្តាយ ខៀវ មុត ។

ដានី ៖ ខៀវ?

សឿន ៖ ខៀវ មុត ។

ដានី ៖ ខៀវ មុត?

សឿន ៖ បាទ!

ដានី ៖ ខៀវ មុត ។ គាត់?

សឿន ៖ គាត់ស្លាប់ ។

ដានី ៖ គាត់ស្លាប់ពីអង្កាល់ដែរ?

សឿន ៖ ស្លាប់តាំង៦៨ ។

ដានី ៖ ឆ្នាំ៦៨ ។

ដារ៉ា ៖ ស្លាប់មុនគ្រួសារគាត់ទៀត?

សឿន ៖ បាទ!

ដារ៉ា ៖ មានមូលហេតុនៃការស្លាប់?

សឿន ៖ ស្លាប់របស់គាត់ គឺជម្ងឺធម្មតា អត់មានខ្វាច... ។

ដារ៉ា ៖ ជាចាស់ជរា?

សឿន ៖ ហ្នឹង! ចាស់ជរា ។

ដានី ៖ ឪពុកក៏ចឹងដែរ?

សឿន ៖ ឪពុកក៏ចឹងដែរ ។

ដានី ៖ ចុះអ៊ំបងប្អូនបង្កើតប៉ុន្មាននាក់?

សឿន ៖ បងប្អូន៩នាក់ ។

ដានី ៖ ៥នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សឿន ៖ ប្រុសទាំងអស់ ។

ដានី ៖ ចុះទី១ ឈ្មោះអីទៅអ៊ំ?

សឿន ៖ ទី១ ទុំ ធុន ។

ដានី ៖ ទុំ ធុន សព្វថ្ងៃគាត់នៅរស់ ហើយក៏?

សឿន ៖ នៅរស់ ។

ដានី ៖ នៅរស់នៅណាដែរ?

សឿន ៖ នៅស្រុកកំណើត ។

ដានី ៖ នៅស្រុកកំណើត?

សឿន ៖ នៅភូមិ ។

ដានី ៖ ទី២?

សឿន ៖ ទី២ ទុំ សោម ។

ដានី ៖ ទុំ សោម ។ គាត់នៅណាដែរ?

សឿន ៖ គាត់នៅភូមិចក្រី ។

ដានី ៖ ចក្រី សំពៅលូនយើង?

សឿន ៖ បាទ!

ដានី ៖ ភូមិចក្រី?

សឿន ៖ ភូមិចក្រី ឃុំចក្រី ។

ដានី ៖ ទី៣?

សឿន ៖ ទី៣ ទុំ សេង ។

ដានី ៖ ទី៣ ទុំ សេង?

សឿន ៖ បាទ!

ដានី ៖ គាត់នៅណាដែរ?

សឿន ៖ ស្លាប់បាត់ ។

ដានី ៖ គាត់ស្លាប់ពីអង្កាល់?

សឿន ៖ នៅស្រុកនោះស្លាប់...... ។

ដានី ៖ ស្លាប់៨៥?

សឿន ៖ បាទ!

ដានី ៖ ទី៤?

សឿន ៖ ទី៤ ខ្ញុំ ។

ដានី ៖ ទី៤ អ៊ំ ។ អ៊ី៥?

សឿន ៖ ទី៥ ទុំ សៅ ។

ដានី ៖ ទី៥ ទុំ សៅ ។ គាត់នៅណាដែរ?

សឿន ៖ គាត់នៅស្រុក ស្លាប់បាត់ ។

ដានី ៖ គាត់ស្លាប់ហើយ ។ ចឹងបងប្អូនអ៊ំស្លាប់អស់២នាក់ហើយ នៅសល់តែ៣នាក់ទេ?

សឿន ៖ នៅសល់៣នាក់ ។

ដានី ៖ ចឹងអ៊ំខ្ញុំចង់ឲ្យអ៊ំរៀបរាប់ពីជីវិតអ៊ំ ដូចថាតាំងពីក្មេងមក អ៊ំធ្លាប់បានចូលរៀននៅសាលាណា បន្ទាប់ពីរៀនសូត្រហើយ អ៊ំធ្វើអីទៀត អ៊ំអាចអញ្ជើញរៀបរាប់?

សឿន ៖ ខ្ញុំតាំងពីតូចមក គឺនៅវត្តៗត្រពាំងធំ ។ នៅវត្តហើយរៀនសូត្រ នៅវត្តនឹងបានចូលសាលានៅវត្ត រៀនដល់ថ្នាក់ទី៧ ខ្ញុំឈប់រៀន ។

ដារ៉ា ៖ វត្តអីគេ?

សឿន ៖ វត្តត្រពាំងធំ ។

ដារ៉ា ៖ វត្តត្រពាំងធំយើង?

សឿន ៖ បាទ!

ដារ៉ា ៖ កាលនឹងមានចៅអធិការព្រះនាមអីដែរ?

សឿន ៖ ព្រះចៅអធិការនឹង នៅ ។

ដារ៉ា ៖ អូ! ព្រះចៅអធិការឈ្មោះ លោក តា នៅ?

សឿន ៖ បាទ! តា នៅ ស្លាប់បាត់អស់ហើយ ។

ដារ៉ា ៖ ខ្ញុំធ្លាប់ទៅដល់កន្លែងវត្តត្រពាំងធំនឹងដែរ ។ ហើយពេលរៀនបានដល់ថ្នាក់ទី៧ពីដើម?

សឿន ៖ ពីដើម ។

ដារ៉ា ៖ ចឹងថ្នាក់ទី៧ យើងចេះសរសេរ ចេះអីខ្លះ?

សឿន ៖ ចេះសរសេរចេះអានច្បាស់ ។

ដារ៉ា ៖ បើធៀបមកឥឡូវថ្នាក់ទីប៉ុន្មាន?

សឿន ៖ ឥឡូវ ។

ដារ៉ា ៖ យើងរាប់ពីទី១២មកកាលនឹង?

សឿន ៖ រាប់ពី១២ ។

ដារ៉ា ៖ ១២ ១១ ១០អីចឹង?

សឿន ៖ បាទ! ១២ ១១ ១០ ៩ ៨ ៧ ។

ដារ៉ា ៖ អានឹងយើងប្រឡងថ្នាក់បឋមភូមិនៅ?

សឿន ៖ បាទ! ប្រឡង ។

ដានី ៖ ប្រឡងឌីប្លូម ហើយប្រឡងកាលេស?

សឿន ៖ មិនមែនឌីប្លូមទេ កាលេស ។

ដារ៉ា ៖ គេហៅប្រឡងកាលេស?

សឿន ៖ ថ្នាក់ទី៧ហ្នឹង ប្រឡងកាលេស ។

ដារ៉ា ៖ ចឹងពូបានប្រឡងជាប់ទេ?

សឿន ៖ បានប្រឡង អត់ជាប់ ។

ដារ៉ា ៖ ប្រឡងជាប់អត់?

សឿន ៖ អត់ ។

ដារ៉ា ៖ អត់ជាប់?

សឿន ៖ បាទ! បានរៀនដល់ថ្នាក់ទី៧ហ្នឹង ឈប់ប្រឡង អត់បានជាប់ទេ ។ អត់ជាប់ក៏ឈប់រៀន ជួយធ្វើស្រែឪពុកម្ដាយ ។

ដារ៉ា ៖ កាលហ្នឹងមានបានចាំឈ្មោះ លោកគ្រូ អ្នកគ្រូបង្រៀនលោកពូទេ បានរៀនលោកគ្រូណាខ្លះ?

សឿន ៖ រៀនជាមួយ គ្រូ ប៊ួន, ប៉ុនគាត់ស្លាប់អស់ហើយ ។ គ្រូ គាន់ ។

ដារ៉ា ៖ គ្រូ គាន់?

សឿន ៖ គ្រូ ស្រ៊ុន ។

ដារ៉ា ៖ គ្រូ ស្រ៊ុន ។

សឿន ៖ គ្រូ ស្រ៊ុន ថ្នាក់ទី៧ ។

ដារ៉ា ៖ ចឹងពេលដែលប្រឡងអត់ជាប់ចឹង អ៊ំបានឈប់រៀន?

សឿន ៖ សម្រាក បាទ! ។

ដារ៉ា ៖ ឈប់រៀនហើយ?

សឿន ៖ ធ្វើស្រែ ។

ដារ៉ា ៖ ធ្វើស្រែ កាលនឹងអ៊ំរៀនបានថ្នាក់ទី៧?

សឿន ៖ ត្រឹមទី៧នឹង ។

ដារ៉ា ៖ ឆ្នាំណា?

សឿន ៖ ឆ្នាំ៦០ ។

ដារ៉ា ៖ ឆ្នាំ៦០នោះ?

សឿន ៖ បាទ! ចុង ចូល៦១ខ្ញុំមកធ្វើស្រែ ចូល៦២ខ្ញុំយកគ្រួសារ ។

ដារ៉ា ៖ ចឹងអ៊ំរៀបចំគ្រួសារតាំងឆ្នាំ៦២មក?

សឿន ៖ បាទ! ឆ្នាំ៦២ ។

ដារ៉ា ៖ ដែលគ្រួសារអ៊ំរាល់ថ្ងៃហ្នឹង?

សឿន ៖ បាទ! គ្រួសាររាល់ថ្ងៃ ។

ដារ៉ា ៖ អូ! មកបានជាប់លាប់មករហូត ។

សឿន ៖ ហ៎!

ដារ៉ា ៖ ហើយពេលមានគ្រួសារហ្នឹង អ៊ំមានរបរអី រកស៊ីដែរក្នុងភូមិនឹង?

សឿន ៖ ពេលមានគ្រួសារ គឺធ្វើស្រែ អត់មានធ្វើអីទេ ។ ពេលចប់កិច្ចការស្រែនឹង គឺចេញដើរស៊ីឈ្នួលគេ ពេលរដូវទំនេរ ។

ដារ៉ា ៖ ស្រែកាលជំនាន់នឹង អ៊ំមានប៉ុន្មានហិចតាទៅ?

សឿន ៖ ស្រែជំនាន់នឹង ពុកចែកមកបានដី២ហិចតាដាង ។

ដារ៉ា ៖ ២ហិចតាដាង ច្រើនដែរតើ?

សឿន ៖ បាទ! គ្រប់គ្រាន់ម៉ាគ្រួសារ ។

ដារ៉ា ៖ ធ្វើស្រែប៉ុន្មានដង ក្នុងម៉ាឆ្នាំ?

សឿន ៖ ធ្វើតែម្ដង ។

ដារ៉ា ៖ ធ្វើតែម្ដង?

សឿន ៖ បាទ!

ដារ៉ា ៖ ហើយការហូបចុកអីគ្រប់គ្រាន់ទេ?

សឿន ៖ គ្រប់គ្រាន់ ហូបចុកធម្មតា ។

ដានី ៖ ចុះអ៊ំថាពេលយើងរដូវទំនេរ យើងដើរស៊ីឈ្នួលៗធ្វើអីទៅ?

សឿន ៖ ស៊ីឈ្នួល ដើរធ្វើកម្មករកាប់ ។

ដារ៉ា ៖ កម្មករ នៅក្នុងភូមិនឹងដែរ ឬក៏?

សឿន ៖ អត់ទេ ចេញក្រៅភូមិ ។

ដារ៉ា ៖ ចេញទៅតាមស្រុក?

សឿន ៖ មកធ្វើកម្មករទៅកំពង់សោម នៅកោះកុង ទៅវៃថ្មវៃអី គាស់ថ្មធ្វើកាប៉ាល់ហោះ ។

ដាវ៉ា ៖ អូ! កាលនឹងគេចាប់ផ្ដើមសាងសង់ព្រលានយន្តហោះ?

សឿន ៖ សាងសង់ព្រលានយន្តហោះនៅកោះកុង ។

ដាវ៉ា ៖ នៅកោះកុង នៅកំពង់សោម?

សឿន ៖ បាទៗ ។

ដាវ៉ា ៖ ចឹងពេលទំនេរ នៅរដូវណាពេលពូទំនេរ?

សឿន ៖ ពេលទំនេរ គឺស្ទូងហើយ ខែ១០ ១១ហ្នឹង ។

ដាវ៉ា ៖ ពេលហ្នឹងទំនេរ ចឹងយើងដើរ?

សឿន ៖ បាទ! ដើរ ពេលច្រូតមកវិញ ខែ១២ ទៅម៉ាខែជាង ត្រឡប់ចូលផ្ទះវិញ ។

ដាវ៉ា ៖ ចឹងកំឡុងពេលហ្នឹងជីវភាពយ៉ាងម៉េចដែរ?

សឿន ៖ កំឡុងពេល ជីវភាពរកវាបានគ្រាន់ទប់ទល់ក្នុងគ្រួសារ ម៉ាគ្រប់ ។

ដាវ៉ា ៖ ហើយកាលនឹងមាន ពេលដែលទៅធ្វើកម្មករអី អ្នកនៅភូមិនៅអីគេទៅចឹងដូចពូដែរ?

សឿន ៖ នៅភូមិខ្លះគេចេញទៅនេះទៅនោះ ។ ខ្ញុំទៅនោះតែឯង ខ្លះគេមកបាត់ដំបង ខ្លះមកពោធិ៍សាត់ វាចឹង ។

ដាវ៉ា ៖ ហ្នឹងតាមដែលយើងស្គាល់គ្នីគ្នាចឹងទៅ?

សឿន ៖ តាមស្គាល់គ្នា ។

ដាវ៉ា ៖ ហើយលោកអ៊ំរៀបការបានប៉ុន្មានឆ្នាំ ទើបមានកូនចៅអីទៅ?

សឿន ៖ ការបាន២ឆ្នាំ ៦៤មានកូន ។

ដាវ៉ា ៖ កូនទី១អ៊ំស្រី ប្រុស?

សឿន ៖ ស្រី ។

ដាវ៉ា ៖ ស្រី អ៊ំការឆ្នាំ៦២ ហើយការបាន២ឆ្នាំ ៦៤ចឹង?

សឿន ៖ បាទ!

ដាវ៉ា ៖ ចឹងកូនស្រីរបស់អ៊ំអាយុច្រើន?

សឿន ៖ អាយុច្រើន វាចាស់ ។

ដានី ៖ គាត់នៅហ្នឹងដែរ?

សឿន ៖ នៅបឹងបេង ។

ដានី ៖ បឹងបេង នៅខាងសំឡូតវិញ?

សឿន ៖ នៅខាងម៉ាឡៃ ។

ដានី ៖ ម៉ាឡៃ បឹងបេង ។ គាត់ឈ្មោះអីដែរ?

សឿន ៖ ទុំ សាម៉េត ។

ដានី ៖ ទុំ សាម៉េត ។

សឿន ៖ ស្រី ។

ដារ៉ា ៖ ហើយដល់ពេលដល់ឆ្នាំ៦៤ បានអ៊ំបានកូនស្រី១?

សឿន ៖ បាទ!

ដារ៉ា ៖ ពេលនឹងអ៊ំទៅណាមកណាទៀតដែរ ឬក៏នៅក្នុងភូមិនឹងតែម្តង?

សឿន ៖ នៅក្នុងភូមិ ។

ដារ៉ា ៖ នៅបន្តទៀត?

សឿន ៖ បន្តទៀត ។

ដារ៉ា ៖ នៅក្នុងភូមិនឹង ក្នុងឆ្នាំ៦៤ មានជាចលនា ជាអីនៅ?

សឿន ៖ អត់មាន ។

ដារ៉ា ៖ ដូចថាជាចលនាកុម្មុយនីស្ត ឬក៏មានជាបាតុភាព ជាស្អីមួយ អត់ទាន់មាន?

សឿន ៖ អត់ទាន់មានស្ងាត់សូន្យ ធម្មតាសម័យសង្គមរាស្ត្រនិយម ។

ដានី ៖ ដល់ចឹងអ៊ំនៅធ្វើអីទៀត កាលពីបន្តមក?

សឿន ៖ ខ្ញុំនៅធ្វើតែស្រែ ។

ដារ៉ា ៖ ធ្វើស្រែមករហូត?

សឿន ៖ ធ្វើស្រែ ។

ដានី ៖ ធ្វើស្រែរហូតដល់ពេលណា?

សឿន ៖ រហូតដល់ពេលមានព្រឹត្តិការណ៍ ។ រហូតមកមានព្រឹត្តិការណ៍ក៏ខ្ញុំធ្វើស្រែដែរ ។

ដារ៉ា ៖ ព្រឹត្តិការណ៍នឹង សំដៅលើព្រឹត្តិការណ៍អី?

សឿន ៖ ព្រឹត្តិការណ៍ដែលគេធ្វើរដ្ឋប្រហារ ។

ដារ៉ា ៖ សម្តេចនឹង?

សឿន ៖ សម្តេច ឆ្នាំ៦៨ ។

ដារ៉ា ៖ ឆ្នាំ៦៨?

សឿន ៖ បាទ!

ដារ៉ា ៖ ៦៨ ហើយ៧០?

សឿន ៖ ឆ្នាំ៦៨ ៦៩ហ្នឹង ។ ហ្នឹងខ្ញុំចេញទៅ ដល់ពេលធ្វើរដ្ឋប្រហារ ខ្ញុំមកដល់ផ្ទះ ។

ដានី :  បាន័យថាអ៊ំចេញពីផ្ទះឆ្នាំ៦៨ៗ ពេល?

សឿន : ខ្ញុំទៅម៉ាខែ ២ខែ ខ្ញុំត្រឡប់មក ។

ដារ៉ា :  ទៅតែពីពេលទំនេរ?

សឿន : ពេលទំនេរនឹង ។

ដារ៉ា :  ទៅតែពីពេលទំនេរពីដកស្ទូងនឹងទេ?

សឿន : ពេលទំនេរ ទៅជួយដកស្ទូង ទៅ២ខែ យ៉ាងយូរ៣ខែត្រឡប់មកវិញ ។

ដារ៉ា :  តាមពិត បើនិយាយទៅអ៊ំស្រុកកំណើតនៅជាមួយតាម៉ុកដែរ?

សឿន : គាត់នៅភូមិផ្សេងគ្នា ។

ដារ៉ា :  នៅភូមិផ្សេងគ្នា តែឃុំជាមួយគ្នា?

សឿន : ឃុំជាមួយគ្នា ។

ដារ៉ា :  ចឹងពេលនឹងអ៊ំបានស្គាល់តាម៉ុក តាំងពីនឹងមកដែរ?

សឿន : ស្គាល់តាំងពីនៅរៀន ព្រោះកូនគាត់ក៏ធ្លាប់រៀនជាមួយខ្ញុំ ។

ដារ៉ា :  អូ! កូនតាម៉ុកហ្នឹង ។

ដានី :  កូនមួយណា ដែលរៀនជាមួយ?

សឿន : ប៉ែ ខ្ញុំ ស្ទាប់បាត់អស់ហើយ ។

ដានី :  ប្រពន្ធតាមុតនឹង?

សឿន : ប្រពន្ធតាមុត ។

ដារ៉ា :  តែអ៊ំ មិនមែនស្រករជាមួយតាម៉ុកទេ?

សឿន : អត់ៗ ។

ដារ៉ា :  អត់ស្រករគ្នាទេ?

សឿន : អត់ស្រករគ្នាទេ ។

ដារ៉ា :  ចឹងពេលដែលអ៊ំនៅរៀននឹង កាលនឹងតាម៉ុកគាត់ធ្វើអីវិញ ជាគ្រូ ឬជា?

សឿន : កាលខ្ញុំនៅរៀន ឃើញគាត់ដួញឈើៗដួញអី ជួយក្រាក់ លក់ដូរ ដូចទិញក្រាក់ពីនេះទៅលក់នោះ ។

ដារ៉ា :  ដែលទិញឈើ ផ្ទះគេរុះឈើអីនឹង?

សឿន : បាទ! យកឈើក្រាក់ ចាស់ដូចថាគេត្រូវការលក់អី ទិញថ្មី គេលក់ផ្ទះនឹងទិញឈើធ្វើថ្មីទៀត ឬមួយគ្នាអ្នកកុន(ទាល់) លក់ផ្ទះចាយ...។

ដារ៉ា :  ចឹងដល់ឆ្នាំ៦០ អ៊ំថា៦៨ ៦៩ ដែលមានរដ្ឋប្រហារ?

សឿន ៖ ចុង៦៨ មានរដ្ឋប្រហារក្នុងផ្សារអន្លុងតាសោម ។

ដានី ៖ អូ! មានជាសកម្មភាព ជារដ្ឋប្រហារ?

សឿន ៖ បាទ!រដ្ឋប្រហារ ទាហានបាញ់ប្រជាជន អានឹងខ្ញុំអត់ឃើញទេ ប៉ុនខ្ញុំចេញពីកំពង់សោមមក ។ មកដល់ចុះពីឡានទៅ ដើរទៅឃើញមានខ្មោចដាប់នៅតាមផ្លូវ ។

ដារ៉ា ៖ នៅតាមផ្លូវៗណា?

សឿន ៖ ផ្លូវជាតិលេខ១២ ផ្លូវពីអន្លុងតាសោមមកតាកែវ ។

ដារ៉ា ៖ អូ! ពីអន្លុងតាសោម ទៅតាកែវ?

សឿន ៖ បាទ! មកផ្លូវលេខ៣ ខ្ញុំចុះពេទ្យរបេងនៅតាកែវ ហើយឡើងជិះឡាំប៉ាតាមកអន្លុងតាសោម ។ ជិះមកតាមផ្លូវ មានឃើញសាកសពដាប់នៅតាមផ្លូវ សាកសពប្រជាជននឹងឃើញដាប់នៅនឹង ខ្ញុំរូតមកដល់ផ្ទះ ។ ហើយដើរមក ទាហានក៏មើលលើមើលក្រោមដែរ ប៉ុន្តែខ្ញុំចេះដើរធ្វើព្រងើយមក ។

ដារ៉ា ៖ ទាហាននឹង គឺទាហាន លន់ នល់?

សឿន ៖ ទាហាន សីហនុ ។

ដារ៉ា ៖ ទាហាន សីហនុ?

សឿន ៖ ហ្នឹង ។

ដារ៉ា ៖ ចុះពេលនឹង មានជាប្រទូសប្រទាសគ្នាជាមួយទាហានលន់ នល់ ឬក៏ម៉េច?

សឿន ៖ អត់មានប្រទូសប្រទាសគ្នាប្រជាជន ដឹងម៉េចពេលនឹងខ្ញុំមកដល់ឃើញសាកសពស្លាប់ មកដល់ផ្ទះ ថាគេធ្វើរដ្ឋប្រហារ ធ្វើបាតុកម្មនៅអន្លុងតាសោម ហើយទាហានបាញ់ ។ ខ្ញុំមកដល់ផ្ទះសួរទៅ ។

ដារ៉ា ៖ ចឹងនៅក្នុងភូមិ គេមានជជែកគ្នាទូលំទូលាយ ពេលទាក់ទងនឹងរឿងរដ្ឋប្រហារគេបាញ់សម្លាប់ពេលហ្នឹង?

សឿន ៖ ពេលហ្នឹងទូលំទូលាយ និយាយគ្នាធម្មតា ។

ដារ៉ា ៖ ចុះពេលនឹង ប្រជាជន គាត់ធ្វើជារដ្ឋប្រហារ បាតុកម្មជាស្អី បានជាទាហាននឹង?

សឿន ៖ មិនដឹងយ៉ាងម៉េច គាត់ធ្វើបាតុកម្ម ដឹងយ៉ាងម៉េច ខ្ញុំមកដល់ឃើញស្លាប់ ហើយដល់ផ្ទះក៏សួរប្រជាជន ។ ហើយទាហាននៅបន្ទាយក្នុងភូមិនឹងក៏នៅដែរ នៅផ្ទះបៀតខ្ញុំនឹង ។ ហើយមកដល់បានប៉ុន្មានថ្ងៃ ក៏ទាហាននឹងចេញពីបន្ទាយនឹងទៅទៀតទៅ ។

ដារ៉ា ៖ ចឹងអត់ដឹងរឿងរ៉ាវច្បាស់លាស់?

សឿន ៖ អត់ដឹងច្បាស់លាស់ទេ ។ ពេលទាហាននឹងចេញទៅ វាអត់ហ៊ានយកកាំភ្លើងទៅ ទាហាន វា

យកមកផ្ញើខ្ញុំ ចុះធ្លាប់ស្គាល់គ្នា ។

ដារ៉ា ៖ ដល់ចឹងទៅ ពេលមានរឿងរ៉ាវចឹងទៅ នៅក្នុងភូមិអ៊ំ មានសភាពយ៉ាងម៉េចទៅ ពេលនឹង?

សឿន ៖ ដែលពេលរឿងរ៉ាវប៉ុននឹង ប្រជាជនខ្លះរៀងផាកមកលិចមក ខ្លះនៅធម្មតាអត់ទាន់មានអីទេ ឃើញសកម្មភាពនឹង អត់ទាន់មានដឹងអីទេ ហើយទាហានក៏ចេញអស់ទៅ ។

ដានី ៖ ចេញពីភូមិពូ?

សឿន ៖ ចេញពីភូមិបន្ទាយ នៅជាប់ភូមិ ។ ហើយពេលចេញមក ទាហានវាអត់ហ៊ានយកកាំភ្លើងទៅ ។

ដារ៉ា ៖ ហើយដល់ចឹងទៅ ផ្ញើនឹងអ៊ំ?

សឿន ៖ ទុកខ្ញុំ២ដើម ទុកនឹងផ្ទះនឹង ។

ដារ៉ា ៖ មាន២ដើម?

សឿន ៖ បាទ! កាលវីករត់ចូលមក ។

ដារ៉ា ៖ ហើយកាំភ្លើងម៉ាកអីទៅ?

សឿន ៖ កាំភ្លើងគីលីដូ(ស្តាប់មិនច្បាស់) អា៨គ្រាប់ ។ កាំភ្លើងសុទ្ធតែកាំភ្លើងបារាំង ។

ដារ៉ា ៖ ហើយពេលដែលមានបាតុកម្មចឹង អ្នកណាដឹកនាំបាតុកម្ម ហើយអ៊ំដឹងទេ?

សឿន ៖ ខ្ញុំអត់បានដឹង មកដល់ឃើញស្វាត់ ។

ដារ៉ា ៖ ចុះដូចតាម៉ុកតាអី?

សឿន ៖ ពេលនឹងអត់ឃើញ ។

ដារ៉ា ៖ អត់ឃើញ?

សឿន ៖ បាទ! អត់មានឃើញ ។

ដានី ៖ ចឹងបន្ទាប់ពីមានបាតុភាពនឹងកើតឡើងចឹងទៅ អ៊ំមិញថាបានទាហាន លន់ នល់ យកកាំភ្លើងមកទុកនៅអ៊ំទៀត?

សឿន ៖ បាទ! ទុក២ដើម ។

ដារ៉ា ៖ ហើយទៅបាត់ទៅ?

សឿន ៖ បាទ! ទៅបាត់ ចេញទៅគគីរ ។

ដារ៉ា ៖ ហើយបន្ទាប់មក?

សឿន ៖ ចេញទៅគគីរ ដល់ពេលនេះគេមានចលនាគេចូលមក ប៉ុនមិនស្គាល់ឈ្មោះណា អ្នកផ្សេងគេមកបំផុសបំផុលមកថាចេះថាចុះទៅណា ។ ថាទាហាន លន់ នល់ ប៉ះបោរទម្លាក់សីហនុចេះៗទៅ ។

ដារ៉ា ៖ មានខាងណាដែលមកឃោសនាចឹង?

សឿន ៖ ខាងខ្មែរក្រហម ។

ដារ៉ា ៖ ខាងខ្មែរក្រហម?

សឿន ៖ បាទ! ហើយខ្ញុំក៏ប្រគល់កាំភ្លើងឲ្យគេទៅ ។

ដារ៉ា ៖ ចឹងពេលនឹង អ៊ំចាប់ផ្ដើមព្ទខ្មែរក្រហម?

សឿន ៖ បាទ! ព្ទខ្មែរក្រហម ពេលនឹង ។

ដារ៉ា ៖ ចុះពីមុនមកដែលព្ទ?

សឿន ៖ អត់ដែលព្ទ ។

ដារ៉ា ៖ អត់ដែលព្ទសោះ?

សឿន ៖ បាទ!

ដារ៉ា ៖ ចឹងចាប់ពីពេលមានបាតុកម្មមក អ៊ំចាប់ផ្ដើមព្ទ?

សឿន ៖ បាទ! ព្ទសូរមានខ្មែរក្រហម មានអី មានចលនា ។

ដារ៉ា ៖ ចលនានឹងមកដល់ភូមិអ៊ំម៉េង?

សឿន ៖ ដល់ភូមិៗ ប្រជាជននៅនឹងទាំងអស់គ្នាក្នុងភូមិនឹង អត់មានអ្នកណាចេញទៅណាទេ ។ ដល់ពេលគេបាន ដល់ឆ្នាំ៧០ បានមានសភាពការណ៍ យួន ធ្វើវិទ្ធង្សនាមក ។

ដារ៉ា ៖ ឆ្នាំ៧០ ចាប់ផ្ដើមមានយួន ធ្វើវិទ្ធង្សនាមក?

សឿន ៖ បាទៗ វិទ្ធង្សនាមក វាចេញប្រតិបត្តិការណ៍ពីអន្លុងតាសោមមកលិចមក មានរថក្រោះមានអី ឃើញចាប់ប្រជាជនចាប់អី ។ ហើយពួកខ្ញុំនឹង ខ្លះប្រជាជននឹងនាំគ្នារត់ចូលព្រៃ ។ ចូលព្រៃទៅដល់ពេលវាអត់មានមនុស្ស វាប្លន់ដាក់ភូមិដាក់អីទៅ ។

ដារ៉ា ៖ មានស្លាប់ប្រជាជនអីដែរ?

សឿន ៖ មានស្លាប់ប្រជាជន ហើយចាប់នារីៗស្រាត នៅម្ដុំភូមិខាងត្បូងខ្ញុំ ភូមិប៉ែនមាស ។ វាទៅស្នាក់នៅនឹងម៉ាយប់ រថក្រោះអីនឹងទៅស្នាក់នៅនឹង ។ វាធ្វើអន្តរាគមន៍តាមផ្លូវនឹងម៉េង ទៅត្បូងទៀតទៅ ។

ដារ៉ា ៖ ទៅត្បូងទៅតាមភូមិណាវិញ?

សឿន ៖ ទៅត្រាំកក់ទៅ ។

ដារ៉ា ៖ ទៅត្រាំកក់?

សឿន ៖ បាទ! ត្រាំកក់ទៅត្បូងទៀតទៅ អង្គរជ័យ ទៅអី ទៅត្បូងចូលដល់យួន ។

ដារ៉ា ៖ ដែលខ្មែរក្រហមមកធ្វើការឃោសនាដំបូង អ្នកណាគេ ស្គាល់ឈ្មោះ ធ្លាប់ព្ទឈ្មោះដែរ?

សឿន ៖ អត់មានស្គាល់ឈ្មោះ ភ្លេចឈ្មោះអស់ ។

ដារ៉ា ៈ ចុះពេលនឹង អ៊ំបានប្រគល់កាំភ្លើងឲ្យទៅខាងខ្មែរក្រហម?

សឿន ៈ បាទ! ខាងខ្មែរក្រហម ខ្ញុំពីដើម ខ្ញុំអត់មានទុកទេ ។

ដារ៉ា ៈ គេអត់មានចោទ អីយ៉ាងម៉េចៗ?

សឿន ៈ អត់មានចោទថាអី ពេលនឹង អត់មានចោទថាអី ព្រោះពេលនឹង ក្រោយប្រគល់ ទាហានរត់បានប៉ុន្មានថ្ងៃ ទាហាននឹងរត់ចូលមកវិញ ។

ដារ៉ា ៈ រត់ចូលមកវិញ ចុះមិនសួររកកាំភ្លើង?

សឿន ៈ ចូល វាអត់សួរទេ រត់ចូលមកវិញ យកមកទុកភូមិមួយ ។ ពួកក្រុមគេនឹងក្រុមខ្មែរក្រហមនឹងនាំទាហាននឹងទៅទុកភូមិមួយ នៅភូមិក្អែបអាភូមិនៅធាតុភូមិខ្ញុំ ។ ទុកនៅនឹងប្រមូលទាហាន ។

ដារ៉ា ៈ ធាតុអីគេ?

សឿន ៈ ធាតុភូមិខ្ញុំ ។

ដារ៉ា ៈ ធាតុភូមិខ្ញុំ?

សឿន ៈ បាទ! យកទៅទុកនៅនឹង ទុកទាហាននឹង ។ ដល់ល្ងាចឡើងបាន២យប់ ក៏ចាប់ផ្ដើមសួរកាំភ្លើងបាញ់គ្នា ។ បាញ់ខ្លះរបួស ខ្លះស្លាប់ ទាហាន ពួកខ្ញុំក៏ទៅមើលៗឃើញទាហានដែលធ្លាប់នៅជាមួយនឹង នៅនឹងភូមិនឹង ។ ឃើញគ្នាត្រូវរបួសបាក់ក្លៅ ក៏សែងយកមកព្យាបាលគ្នានៅផ្ទះមក ។ ប៉ុនព្យាបាលអត់ជាគ្នា ចុះយើងមានថ្នាំពេទ្យណា ខិតដល់អានឹងអត់ ។ មានចេញចូលទៅណា បើបិទផ្លូវអស់ហើយ គ្នាស្លាប់ទៅ ។

ដារ៉ា ៈ ហើយឈ្មោះអីដែរ ទាហាននឹង ចាំឈ្មោះ?

សឿន ៈ ឈ្មោះ ពូ អំ ។

ដារ៉ា ៈ ពី អំ?

សឿន ៈ បាទ!

ដារ៉ា ៈ ហើយការបាញ់គ្នានឹង បាញ់ជាមួយខាងណា?

សឿន ៈ បាញ់ជាមួយខ្មែរក្រហម ។

ដារ៉ា ៈ បាញ់ជាមួយខ្មែរក្រហមហ្នឹង?

សឿន ៈ បាទ!

ដារ៉ា ៈ ចុះដល់ពេលពូជួយខាងទាហាន លន់ នល់ ចឹងទៅ តើពូមានទោសពៃរ៍ទេ ក្រោយមក?

សឿន ៈ អត់មានអីគ្នាក្នុងភូមិនឹង ទៅទាំងអស់គ្នាទៅជួយយកមកមើលគ្នាទៅ ចុះមនុស្សធ្លាប់នៅជាមួយគ្នា ទៅជួយយកអសារគ្នាទៅ ។

ដារ៉ា ៈ ហើយចុះក្រោយពីមានបាតុភាពបាញ់គ្នាចឹងទៅ មានរឿងរ៉ាវអីទៀតនៅក្នុងភូមិនឹងបន្ត

ទៀត?

សឿន ៖ អត់មានរឿងរ៉ាវអីទៀតទេ នៅក្នុងភូមិនឹង ស្គាត់ទៅទាំងអស់ ស្ងាត់រហូតបានមានចលនាគេបំផុសឡើង ។

ដារ៉ា ៖ ចឹងចលនាខ្មែរក្រហមចាប់ផ្ដើម បំផុសកាន់តែខ្លាំងក្នុងភូមិពូ?

សឿន ៖ បាទ! ចុះអត់មាននេះទេ អត់មានខាងក្នុងចេញចូលទៅខាងនឹងក៏អត់មានចេញចូលមកក្នុងដែរ ។

ដារ៉ា ៖ ចឹងដូចជាតំបន់មួយស្វ័យត ឬក៏តំបន់រំដោះរបស់ខ្មែរក្រហម?

សឿន ៖ បាទ! តំបន់រំដោះរបស់ខ្មែរក្រហម ។

ដារ៉ា ៖ ពួក លន់ នល់ អត់ចូលបាន?

សឿន ៖ អត់ចូលបាន ។

ដារ៉ា ៖ នៅភូមិអ៊ី ស្រុកកំណើតអ៊ីម៉ង?

សឿន ៖ ហ្នឹង ស្រុកកំណើតខ្ញុំ លិចអង្គតាសោម ។ វានៅៗបន្ទាយអង្គតាសោម ។

ដារ៉ា ៖ នៅកន្លែងផ្លូវថ្នល់បែកទៅតាកែវ ហើយមួយទៀតទៅកំពត?

សឿន ៖ បាទ! នៅកន្លែងនឹង បន្ទាយវានៅនឹង បន្ទាយទាហាន លន់ នល់ ។

ដារ៉ា ៖ ពួកទាហានលន់ នល់?

សឿន ៖ បាទ! នៅនឹង ។ វានៅនឹង មានសកម្មភាព វាម៉ាខែពីរខែវាច្បាំងម្ដង ។

ដារ៉ា ៖ ច្បាំងទៅខាងត្រពាំងធំ?

សឿន ៖ បាទ! ច្បាំងត្រពាំងធំ ។

ដារ៉ា ៖ អានឹងទៅខាងលិច?

សឿន ៖ ទៅលិច ។ អាផ្លូវបែកមកលិច ។ អាផ្លូវមួយទៅតាកែវចេះ អាមួយបែកទៅលិចចេះ ហើយអាដើងត្បូងអានឹងចេញពីភ្នំពេញទៅកំពត ។

ដារ៉ា ៖ ចឹងចាប់ពីកន្លែងផ្លូវ៤ បែកជា៤អង្គតាសោមនឹង ទៅលិចនឹង គឺថាខ្មែរក្រហមនៅនឹងម៉ងអត់មានចេញចូលបាន?

សឿន ៖ បាទ! ចេញពីនឹងទៅ ។

ដារ៉ា ៖ អត់មានចេញចូលបាន?

សឿន ៖ អត់ចេញចូលបាន ។

ដារ៉ា ៖ អានឹងពីឆ្នាំ៧០?

សឿន ៖ បាទ! ៧១ ។

ដារ៉ា ៖ ៧០ ៧១?

សឿន ៖ ហ្អឹង! ៧១ ។ ៧០នៅចេញចូលបាន ។

ដារ៉ា ៖ ចឹងដល់ពេល៧១ ខ្មែរក្រហមនៅម៉ាត្រពាំងធំនឹង ហើយនៅខាងលិចអន្លុតាសោមនឹង?

សឿន ៖ នៅលិចអន្លុតាសោម ។

ដារ៉ា ៖ ចឹងមានចលនា ជាការបង្កើតជារដ្ឋអំណាចជាអីនៅ ពេលនឹង?

សឿន ៖ នឹងគេមានបង្កើតជារដ្ឋអំណាចហើយ ។

ដារ៉ា ៖ រដ្ឋអំណាចខ្មែរក្រហម?

សឿន ៖ បាទ! រដ្ឋអំណាចខ្មែរក្រហម មានចាត់តាំងភូមិឃុំ ។

ដារ៉ា ៖ ចុះពេលនឹង អ៊ំត្រូវបានជ្រើសរើស ឬចាត់តាំងយ៉ាងម៉េចដែរ?

សឿន ៖ អត់ទេពេលនឹង ខ្ញុំនៅជាប្រជាជន ។

ដារ៉ា ៖ នៅប្រជាជន?

សឿន ៖ បាទ!

ដារ៉ា ៖ ហើយបន្តមកទៀតទៅ?

សឿន ៖ គេឲ្យមកយាមតាមផ្លូវ ។

ដារ៉ា ៖ ចូលរួមយាមនឹងគេដែរ?

សឿន ៖ បាទ! ចូលរួមយាមគេ ។

ដារ៉ា ៖ យាម មានកាន់អាវុធកាន់អីដែរ?

សឿន ៖ អត់ទេ ដៃទទេរ ។

ដារ៉ា ៖ ដៃទទេរ?

សឿន ៖ យាម គ្រាន់ចាំជួយសែងរបួសគ្នាទៅវិញទៅមក ពេលទាហានវ៉ៃគ្នាមុខ មានរបួសអី មកចឹង យើងចាំជួយសែងគ្នា សែងស្នាក់ពីភូមិមួយទៅភូមិមួយ យើងមកវិញ ។ ដល់ភូមិ នោះគេយកទៅទៀត ហើយភូមិនោះគេតទៅទៀត ដល់ភូមិមួយគេយកទៅទៀត ។

ដារ៉ា ៖ យើងអត់បានដឹងកន្លែងច្បាស់លាស់?

សឿន ៖ បាទ! បានត្រឹមភូមិមួយទៅភូមិមួយ ។

ដារ៉ា ៖ ហើយដល់ចឹង ដល់ឆ្នាំណាបន្តទៀតទៅអ៊ំ?

សឿន ៖ រហូតឆ្នាំ៧០ ៧២ ៧៣ ៧៥ ។ ៧៥ពេលរំដោះហើយនឹង អានឹងបានរំដោះអស់ទាហាន លន់ នល់ នឹងគេចូលកាន់កាប់ម៉ង ខ្ញុំទៅធ្វើស្រែប្រាំង ។

ដារ៉ា ៖ ធ្វើស្រែប្រាំង?

សឿន ៖ ហ្នឹង ៧៦ ចេញទៅធ្វើស្រែប្រាំងនៅតាកែវ ខាងកើតតាកែវ ។

ដាវ៉ា ៖ ធ្វើស្រែប្រាំងនៅតាកែវ នៅស្រុកណា ឃុំណា?

សឿន ៖ នៅ ម៉ុំនឹងវា ឃុំភ្នំដារនេះ ខាងលិចភ្នំដារនេះ ។

ដាវ៉ា ៖ ខាងលិចភ្នំដារ?

សឿន ៖ បាទ! វាលខាងលិចភ្នំដារ ។

ដាវ៉ា ៖ ក្នុងស្រុកអី?

សឿន ៖ ភ្នំដារ ដូចស្រុក ។

ដាវ៉ា ៖ ព្រៃកប្បាស?

សឿន ៖ មិនមែនទេ ។

ដានី ៖ អង្គរបូរី?

សឿន ៖ វាជាប់អង្គរបូរី ជាប់ស្រុកនែក! ។

ដានី ៖ ព្រៃកប្បាសដែរ?

សឿន ៖ ជាប់ព្រៃកប្បាស មានព្រំប្រទល់ជាប់គ្នាព្រៃកប្បាស ៣ស្រុកជាប់គ្នានឹង ។

ដាវ៉ា ៖ ហើយធ្វើស្រែ អ៊ំជាប្រជាជនធម្មតា ឬក៏ជា?

សឿន ៖ ជាមេក្រុម ។

ដាវ៉ា ៖ ជាមេក្រុម?

សឿន ៖ បាទ! នាំគេធ្វើនឹង ។

ដាវ៉ា ៖ បានធ្វើជាមេក្រុមគេ?

សឿន ៖ បានធ្វើមេក្រុម ។

ដាវ៉ា ៖ ហើយពេលនឹង ប្រធានភូមិ ប្រធានឃុំអី ឈ្មោះអីដែរ ហើយអ្នកស្រុកណា?

សឿន ៖ ប្រធានភូមិ ទៅនឹង គឺទៅគ្រប់ភូមិ ទៅនឹង ។

ដាវ៉ា ៖ ទៅចំរុះគ្នា?

សឿន ៖ ទៅចំរុះគ្នា ធ្វើគ្រប់ភូមិទាំងអស់ ហើយភូមិខ្ញុំក៏ទៅធ្វើនៅនឹង គេឲ្យទៅធ្វើស្រែប្រាំង ។

ដាវ៉ា ៖ ចឹងអត់បានរស់នៅភូមិឃុំអ៊ំតទៅទៀតទេ?

សឿន ៖ បាទ! អត់បាននៅគ្រួសារ គ្រប់ភូមិចេញពីនឹង ។

ដាវ៉ា ៖ មកទាំងគ្រួសារម៉ង ឬក៏?

សឿន ៖ អត់ទេ ទៅតែខ្ញុំ ។

ដាវ៉ា ៖ តែម្នាក់ឯងអ៊ំ?

សឿន ៖ នៅតែឯង ។

ដារ៉ា ៖ ចឹងគ្រួសារ?

សឿន ៖ នៅសុទ្ធតែប្រុស។ នៅធ្វើ អត់ស្រីទៅ ។ អូ! ហើយយុវជន យុវនារី ។

ដារ៉ា ៖ តែអ៊ំមានគ្រួសារហើយនឹង ម៉េចចូលជាយុវជនកើត?

សឿន ៖ អត់ទេ វាមកសុទ្ធតែប្រុស។ គេឲ្យធ្វើតែប្រុស។ ស្រីនៅផ្ទះ ។

ដារ៉ា ៖ ដល់ឆ្នាំ៧៥ អ៊ំមានកូនប៉ុន្មាននាក់?

សឿន ៖ ដល់៧៥ កូន៤នាក់ ។

ដារ៉ា ៖ ដល់៧៥ កូន៤នាក់?

សឿន ៖ បាទ!

ដារ៉ា ៖ ចឹងមកដល់ពេល៧៥នឹងទៅ?

សឿន ៖ អូ! ៧៥ កូន៤នាក់ ។

ដារ៉ា ៖ ចឹងកូន៤នាក់នឹង នៅជាមួយគ្រួសារអ៊ំ?

សឿន ៖ នៅជាមួយគ្រួសារ ។

ដារ៉ា ៖ នៅឃុំត្រពាំងធំ?

សឿន ៖ បាទ! ឃុំត្រពាំងធំ ភូមិត្រពាំងជ្រៃ ។

ដារ៉ា ៖ ហើយអ៊ំមកធ្វើស្រែនៅឃុំភ្នំដារនេះវិញ?

សឿន ៖ បាទ! មកធ្វើស្រែនៅឃុំភ្នំដារ ។ ប៉ុនធ្វើមកតែម៉ារដូវនឹង ត្រឡប់ទៅផ្ទះវិញ ។

ដារ៉ា ៖ បានតែម៉ារដូវទេ?

សឿន ៖ បាទ! បានម៉ារដូវនឹង ត្រឡប់ទៅវិញ ពេលដល់រដូវបើគេឲ្យមកទៀតក៏មកទៅ អត់ក៏អត់ទៅ នៅធ្វើផ្ទះទៅ ធ្វើស្រែតាមភូមិ តាមក្រុមសហករណ៍គេ ។

ដារ៉ា ៖ ចឹងកាលនឹងនៅឆ្នាំ៧៥ ខែណា?

ដានី ៖ ពេលយើងបែកភ្នំពេញ ថ្ងៃទី១៧មេសា?

សឿន ៖ បាទ! ១៧មេសា ៧៥ ។

ដានី ៖ ដល់ពេលអ៊ំទៅធ្វើស្រែ ខែប៉ុន្មានទៅ?

សឿន ៖ ដល់ធ្វើស្រែអានឹងទៅដល់ខែ១១ ខែទឹកស្រក់ ១១ ១២នឹង ចាប់ធ្វើរហូតដល់ខែ១ ខែ២ ខែ៣ បានច្រូតហើយ ខែ៣ច្រូត ។ ច្រូតហើយយើងឡើងមកវិញ ខែ៣-៤ ។

ដារ៉ា ៖ ចឹងអ៊ំបានទៅធ្វើស្រែនៅភ្នំដារ ឆ្នាំ៧៥ ខែ១១នឹង តែម៉ារដូវ?

សឿន ៖ បាទ! តែម៉ារដូវ ។

ដារ៉ា ៖ ហើយត្រឡប់មកណាវិញ?

សឿន ៖ ត្រឡប់មកភូមិវិញ ។

ដារ៉ា ៖ ត្រឡប់មកភូមិវិញ?

សឿន ៖ ត្រឡប់មកភូមិវិញ ដល់ចូល៧៦នឹង គេឲ្យមកនៅព្រះនេត្រព្រះនេះ ។

ដារ៉ា ៖ អ៊ំមកនៅព្រះនេត្រព្រះតាំងពីឆ្នាំ៧៦?

សឿន ៖ បាទ!

ដានី ៖ អ៊ំមកមុនគេ ឬយ៉ាងម៉េច?

សឿន ៖ មកគ្នាច្រើន មកស្រុកខ្ញុំនឹង ជាង២០០០នាក់ ។

ដារ៉ា ៖ មកជាប្រជាជនម៉ង?

សឿន ៖ មកជាប្រជាជន គេបាត់តាំងមក ។

ដារ៉ា ៖ ទាំងគ្រួសារៗ?

សឿន ៖ បាទ! មកទាំងគ្រួសារៗ ប៉ុន្តែខ្ញុំមកតែខ្ញុំទេ គ្រួសារអត់ទាន់មក គ្រួសារឈឺ ។

ដារ៉ា ៖ ចឹងក្នុងចំណោម២០០០នាក់នឹង គឺអ៊ំមកក្នុងចំណោម២០០០នាក់នឹង?

សឿន ៖ ហ្នឹង មកក្នុងចំណោម២០០០នាក់នឹង ។

ដារ៉ា ៖ មកព្រះនេត្រព្រះ?

សឿន ៖ បាទ! មកព្រះនេត្រព្រះ ។

ដារ៉ា ៖ មកស្រុកម៉ង?

សឿន ៖ បាទ! មកស្រុកព្រះនេត្រព្រះ ។

ដារ៉ា ៖ មកជាកម្លាំងអីដែរ ដែលមក?

សឿន ៖ កម្លាំងគឺ មកៗធ្វើការ មកធ្វើស្រែធ្វើអី មានអ្នកដឹកនាំមក ។

ដារ៉ា ៖ អ្នកដឹកនាំមកនឹង ឈ្មោះអីដែរ ក្នុងចំណោម២០០០នាក់នឹង?

សឿន ៖ ឈ្មោះ ស្រី ថែម ។

ដារ៉ា ៖ ស្រី ថែម ឬយាយ ថែម?

សឿន ៖ យាយ ថែម ។ ប្តីគាត់ តា ញ៉ែន ។

ដារ៉ា ៖ ប្តីគាត់ឈ្មោះ តា ញ៉ែន?

សឿន ៖ បាទ!

ដារ៉ា ៖ ចឹងតាំងពីឆ្នាំ៧៦នឹង គាត់នាំ?

សឿន ៖ បាទ! គេឲ្យនាំកម្លាំងមក ។

ដាវ៉ា ៖ មកព្រះនេត្រព្រះ?

សឿន ៖ មកព្រះនេត្រព្រះនឹង ។

ដាវ៉ា ៖ មកការផាររដិបូងធ្វើអី នៅព្រះនេត្រព្រះ?

សឿន ៖ ការផាររដិបូងមកដល់ គេប្រគល់ន័ង្គលអីឲ្យប្រគល់គោឲ្យ ដើរភ្ជួរស្រែ ។

ដាវ៉ា ៖ ព្រះនេត្រព្រះនៅម្តុំណា?

សឿន ៖ ទៅភ្ជួរនៅយើង ភ្នំក្រប៉ៅ ធ្វើស្រែនៅភ្នំក្រប៉ៅ ។

ដានី ៖ ភ្នំអីគេ?

សឿន ៖ ភ្នំក្រប៉ៅ ក្រោមនោះ ។

ដាវ៉ា ៖ នៅក្នុងភូមិអីឃុំអី?

សឿន ៖ អានឹងដូចភូមិភ្នំក្រប៉ៅដែរ កាលនឹងអត់មានភូមិមានអី ភ្នំក្រប៉ៅ ភូមិក្រប៉ៅនៅនឹង មាន ប្រជាជននៅនឹង ក៏ភូមិក្រប៉ៅ ។

ដាវ៉ា ៖ ពេលនឹង យាយ ថែម គាត់ធ្វើអីវិញ?

សឿន ៖ គាត់ធ្វើគណៈស្រុក ។

ដាវ៉ា ៖ គណៈស្រុកព្រះនេត្រព្រះ?

សឿន ៖ បាទ! ព្រះនេត្រព្រះ ។

ដានី ៖ តាំងពីឆ្នាំ៧៦?

សឿន ៖ ៧៦ ចុង៧៦ ។

ដាវ៉ា ៖ ចុង៧៦?

សឿន ៖ បាទ!

ដានី ៖ អឹចាំខែ?

សឿន ៖ អត់ចាំទេ ។

ដានី ៖ ប្រហែលជាខែ កាលនឹងអឹប្រៀបធៀបជាខែធ្វើស្រែវិញ ពេលនឹង?

សឿន ៖ ពេលនឹងខែ៨ មកដល់គេចាប់ភ្ជួរ ព្រួស ។

ដាវ៉ា ៖ ចាប់ភ្ជួរព្រួស?

សឿន ៖ ចាប់ភ្ជួរព្រួសវាមានខែ៣ ខែ៨ ស្រែម្តុំយើង ។

ដានី ៖ ចាប់ភ្ជួរព្រួសហេ៎?

សឿន ៖ ហ្នឹង ភ្ជួរព្រួស ។

ដាវ៉ា ៖ ភ្ជួរព្រួសម៉េច ព្រោះវាជិតចូលឆ្នាំ អឹម៉េចមានទឹក មានភ្លៀង?

សឿន ៖ ព្រួសរាំង ។

ដារ៉ា ៖ ព្រួសទាំងរាំង?

សឿន ៖ បាទ! ព្រោះស្រូវឡើងទឹក ធ្វើស្រូវឡើងទឹក ។

ដានី ៖ កាលនឹងខែ៣ ខែ៤ ឆ្នាំណា? អ៊ំមានប្រសាសន៍មិញថា មកចុងឆ្នាំ៧៦?

សឿន ៖ ៧៦ ។

ដានី ៖ ដល់អ៊ំមានប្រសាសន៍មួយសារទៀតថា ប្រហែលជាខែ?

សឿន ៖ ក្បួរនឹងចូលខែ៤ ៧៧ ខែ៤ ខែ៥ ។

ដានី ៖ ចឹងបានន័យថាអ៊ំមកពីតាកែវ មកក្នុងខែ៣ ខែ៤ ៧៧ ឬក៏មកចុងឆ្នាំ?

សឿន ៖ ចុងឆ្នាំ៧៦ ។

ដានី ៖ មកចុងឆ្នាំ៧៦?

សឿន ៖ បាទ!

ដារ៉ា ៖ ចុះអ៊ំពេលនឹង អ៊ំមក អ៊ំបានស្គាល់ យាយ ចែម ច្បាស់ពេលនឹង?

សឿន ៖ បាទ! ស្គាល់ យាយ ចែម ច្បាស់ ។ អានេះអត់ដែលស្គាល់គ្នា ទើបមកពេលនឹងស្គាល់តាមផ្លូវ ចុះកាលណាមកតាមផ្លូវ ដឹងអ្នកគ្រប់គ្រងណាៗ យើងដឹង ទាក់ទងរឿងហូបអីៗសុំគេហូបតាមផ្លូវ ។ យើងដើរទៅទាក់ទងគេបានមានអីហូប មានដឹងកន្លែង ។

ដារ៉ា ៖ ចុះពេល យាយ ចែម មកនឹង គាត់មកទាំងគ្រួសារគាត់ ឬក៏មក?

សឿន ៖ មកទាំងគ្រួសារគាត់ ។

ដារ៉ា ៖ ចុះគាត់ស្រីចឹង គេឲ្យគ្រប់គ្រងមនុស្ស២០០០នាក់ ដឹកនាំមក?

សឿន ៖ បាទ! គ្រប់គ្រង បាទ! ។

ដានី ៖ យាយ ចែម គាត់ធ្លាប់ធ្វើអីកាលពីមុន មកព្រះនេត្រព្រះ?

សឿន ៖ មុនមក យាយ ចែម គាត់ធ្វើជាប់ឆ្នោតសភា ។

ដានី ៖ គាត់ជាប់ឆ្នោតសភា?

សឿន ៖ ហ្នឹង! ប្រចាំមណ្ឌលតាកែវ ។

ដារ៉ា ៖ ប្រចាំមណ្ឌលតាកែវ?

សឿន ៖ បាទ!

ដារ៉ា ៖ ចឹងគាត់សភា សម័យខ្មែរក្រហមនឹង?

សឿន ៖ បាទ! សភាសម័យខ្មែរក្រហម ។

ដារ៉ា ៖ គាត់តំណាងអី តំណាងកសិករ ឬក៏តំណាង?

សឿន ៖ តំណាងកសិករ ។

ដារ៉ា ៖ តំណាងកសិករនៅខេត្តតាកែវម៉ង?

សឿន ៖ បាទ! ខេត្តតាកែវ ។

ដារ៉ា ៖ ជាសភា?

សឿន ៖ បាទ! ជាសភា ។

ដារ៉ា ៖ ប៉ុនបើគាត់តំណាងចឹង ម៉េចបានគាត់ស្មើត្រឹមគណៈស្រុកចឹង?

សឿន ៖ ដល់ពេលមកដល់នេះ គាត់ធ្វើការនៅក្នុងស្រុក ផ្ទៃក្នុងគេដឹងម៉េច ប៉ុនវាឃើញគាត់ធ្វើការងារនៅក្នុងស្រុក ។

ដារ៉ា ៖ ស្រុកព្រះនេត្រព្រះនឹង?

សឿន ៖ បាទ! ស្រុកព្រះនេត្រព្រះ គាត់ទាក់ទងទៅភាគ ទៅតំបន់ ។

ដារ៉ា ៖ ពេលមកដល់ព្រះនេត្រព្រះនឹង ចុះគណៈស្រុកគេមុន ទៅណា ហើយឈ្មោះអីដែរ?

សឿន ៖ មកដល់អត់មាន គណៈស្រុកមុនអត់មាន ។ នៅ គេបាដកទៅណាអស់ហើយ នៅគណៈតំបន់ ។

ដារ៉ា ៖ កាលនឹង គណៈតំបន់ឈ្មោះអី?

សឿន ៖ ឈ្មោះ ជៀល ។

ដារ៉ា ៖ ជៀល?

សឿន ៖ បាទ!

ដារ៉ា ៖ តែគណៈស្រុកអត់មានទេ?

សឿន ៖ បាទ!

ដារ៉ា ៖ ដល់ពេល យាយ ចែម មក បាន យាយ ចែម ឡើងជាគណៈស្រុក?

សឿន ៖ បាទ! ឡើងគណៈស្រុក ។

ដារ៉ា ៖ ហើយពេលអ៊ំមកដល់ធ្វើស្រែ ធ្វើចំការ គេបានបែងចែកអ៊ំឲ្យកាន់កងកាន់ក្រុមអីដែរ?

សឿន ៖ គេឲ្យកាន់ក្រុម ឲ្យកាន់កង១ ខ្ញុំឈប់ធ្វើស្រែ គេឲ្យមកលើកប្រឡាយ ។

ដារ៉ា ៖ នៅម្តុំណាវិញ?

សឿន ៖ ម្តុំ មុននឹងលើកប្រឡាយ នៅធ្វើស្រែ ។ យកប្រឡាយចេញពីភ្នំស្រុកទៅអាងត្រពាំងថ្មនឹង ។

ដានី ៖ លើកប្រឡាយមួយណា ប្រឡាយឈ្មោះអី?

សឿន ៖ ចេញពីអាងត្រពាំងថ្ម រហូតទៅឆ្លងកាត់ទៅភូមិទៅខាងកើតភ្នំលៀប អាប្រឡាយមួយខាងកើតភ្នំលៀប ។

ដារ៉ា ៖ គេហៅប្រឡាយអី?

សឿន ៖ ទេ! កាលនឹងអត់មានឈ្មោះទេ ។

ដារ៉ា ៖ ដឹងប្រឡាយគេ ពីត្រពាំងថ្មទៅភ្នំលៀបម៉ង?

សឿន ៖ នឹងទៅភ្នំលៀប ទៅជាប់ដៃទន្លេសាប ទៅវាលក្រោមនឹង តាមវាលនឹង ។

ដានី ៖ ឆ្នាំណា?

សឿន ៖ កាល៧៨ ដើម៧៨ធ្វើប្រឡាយ ។

ដារ៉ា ៖ មានមនុស្សច្រើនទេ ចូលរួមធ្វើប្រឡាយនឹង?

សឿន ៖ ចល័តទាំងអស់វាមាន ៣-៤ស្រុកនឹង ធ្វើប្រឡាយនឹងទាំងអស់គ្នានឹង តាំងពីត្រពាំងថ្ម លើកទំនប់ត្រពាំងថ្ម ចេញចឹងទៅៗក្រោមចឹងទៅ ម៉ាស្រុកព្រះនេត្រព្រះ កម្លាំងរួមម៉ា តំបន់៥ ។ តំបន់យើងបន្ទាយមានជ័យ ។ រួមគ្នាធ្វើនៅនឹងទាំងអស់ ហើយបានបែកគ្នាទៅ ។

ដារ៉ា ៖ ចុះអ៊ំពេលនឹង គ្រួសារអ៊ំមក?

សឿន ៖ មកហើយគ្រួសារ ។

ដារ៉ា ៖ ឆ្នាំណា គ្រួសារអ៊ំមកនៅជាមួយ?

សឿន ៖ មកដើម៧៨ ។

ដារ៉ា ៖ ដើម៧៨ បានគ្រួសារមកពីភូមិនោះ?

សឿន ៖ មកពីភូមិ ។

ដារ៉ា ៖ មកជួបអ៊ំនៅ?

សឿន ៖ បាទ! មកជួបនៅកន្លែងនេះ ។

ដារ៉ា ៖ នៅកន្លែងណាអ៊ំ?

សឿន ៖ នៅព្រះនេត្រព្រះ ។

ដារ៉ា ៖ នៅក្នុងភូមិឃុំអីអ៊ំ?

សឿន ៖ នៅជួបក្នុងភូមិរំដួល ឃុំរំដួល ។

ដារ៉ា ៖ រំដួល ឃុំរំដួល?

សឿន ៖ បាទ! ស្រុកព្រះនេត្រព្រះ ។

ដារ៉ា ៖ ចុះពេលនឹង យាយ បែម គាត់ កន្លែងគាត់ស្នាក់នៅ?

សឿន ៖ ព្រះនេត្រព្រះ ។

ដារ៉ា ៖ នៅកន្លែងណាច្រើនជាងគេ?

សឿន ៖ នៅភូមិព្រះនេត្រព្រះនឹង ។

ដារ៉ា ៖ នៅភូមិព្រះនេត្រព្រះនឹង?

សឿន ៖ បាទ! នៅក្នុងឃុំព្រះនេត្រព្រះ ។ ផ្ទះស្នាក់គាត់ កន្លែងគាត់ធ្វើការនឹង ។

ដារ៉ា ៖ នៅតាមផ្លូវពីបន្ទាយមានជ័យទៅ ។ នៅតាមផ្លូវជាតិយើងម៉ង?

សឿន ៖ នៅជាប់ផ្លូវជាតិ ។

ដារ៉ា ៖ ជាប់ផ្លូវជាតិ?

សឿន ៖ អឺ! ជាប់ផ្លូវជាតិ នៅខាងកើតផ្លូវជាតិ នៅភូមិជាប់ផ្លូវជាតិ ។

ដារ៉ា ៖ ភូមិព្រះនេត្រព្រះ?

សឿន ៖ ភូមិព្រះនេត្រព្រះ អឺ! ភូមិជប់ ។

ដារ៉ា ៖ ភូមិជប់?

សឿន ៖ គាត់នៅភ្នំលៀប ។

ដារ៉ា ៖ បើម៉ាផ្លូវនឹងយើង?

សឿន ៖ នៅភូមិភ្នំលៀបម៉ង ។ ចេញពីព្រះនេត្រព្រះរហូតទៅកើតទៅ ដល់ភ្នំលៀប ។

ដានី ៖ ចឹងគាត់នៅភ្នំលៀប?

សឿន ៖ នឹងនៅភ្នំលៀប ។

ដារ៉ា ៖ ទីស្នាក់ការនៅភ្នំលៀបនឹងម៉ង?

សឿន ៖ កន្លែងស្នាក់ការគាត់នៅភ្នំលៀប ។

ដារ៉ា ៖ នៅផ្ទះប្រជាជន ឬផ្ទះយ៉ាងម៉េច?

សឿន ៖ ផ្ទះនឹង ផ្ទះប្រជាជនៗ គេដកទៅណាអស់ មកដល់អត់មានឃើញម្ចាស់ផ្ទះនៅ ។

ដារ៉ា ៖ ចឹងគាត់គណៈស្រុក គាត់នៅទីតាំងរបស់គាត់នៅកន្លែងភ្នំលៀបនឹង?

សឿន ៖ នឹងនៅភ្នំលៀប ។

ដារ៉ា ៖ ចុះពេលនឹង អ៊ំគេឲ្យធ្វើអីវិញ?

សឿន ៖ ខ្ញុំមេកង នៅធ្វើចល័ត ធ្វើស្រែ ធ្វើទំនប់ ។

ដារ៉ា ៖ មេកងចល័ត?

សឿន ៖ បាទ! ហើយកំពុងធ្វើស្រែ រៀបប្រូតនឹង ក៏គេវៃគ្នាទៀតទៅ ។ ចុង៧០ ជិតចូល៧៨នឹង ព្រឹត្តិការណ៍កើតឡើងរត់ចេញម៉ង ។

ដារ៉ា ៖ រត់ចេញពីភ្នំលៀប?

សឿន ៖ បាទ! ចេញពីភ្នំលៀប ។

ដារ៉ា ៖ ចុះអ៊ំ ម៉េចបានអ៊ំដឹងថា យាយបែមគាត់នៅកន្លែងភ្នំលៀប កាលនឹងអ៊ំធ្វើការអីនៅម្តុំណា បានដឹងថាគាត់?

សឿន ៖ ខ្ញុំនៅខាងកើតភ្នំលៀប នៅធ្វើប្រឡាយខាងកើតភ្នំលៀប ធ្វើមេក្រុម គេហៅមកប្រជុំកន្លែងស្រុកនឹង ។ ហើយគាត់មកប្រជុំនឹង មកជួបគ្នានឹង ធ្វើការអីទៅ ហើយដល់ពេលគេធ្វើប្រឡាយនឹង ម៉ាអាទិត្យ គាត់ចុះទៅធ្វើការម្តង ។

ដារ៉ា ៖ នៅប្រឡាយនឹង?

សឿន ៖ នៅប្រឡាយ ។

ដារ៉ា ៖ គាត់ចុះទៅមើល?

សឿន ៖ ចុះទៅមើល ។

ដារ៉ា ៖ ហើយអ៊ំពីភ្នំលៀប ទៅកន្លែងប្រឡាយនឹងឆ្ងាយទេ?

សឿន ៖ វាល មើលឃើញ ប៉ុនពីចម្ងាយដីនឹង ភ្លេចហើយប៉ុន្មានស្មាន ។ ពីភ្នំលៀបនឹងទៅដីខ្វង់៥គីឡូ ដល់មើលពីភ្នំលៀបទៅឃើញ នៅវែតាមផ្លូវ ៗ ចុះវាលដី ។

ដារ៉ា ៖ នៅភ្នំលៀប មានភ្នំអីផ្សេងទៀតទេ មានឈ្មោះភ្នំអីផ្សេងទៀត?

សឿន ៖ ភ្នំលៀបនឹងវានៅ អានឹងទៅក្រោម ៗ នឹង ភ្នំ៣-៤ ភ្នំតូច ៗ នឹង ។

ដារ៉ា ៖ ភ្នំអីខ្លះទៅអ៊ំ?

សឿន ៖ ភ្នំស្រេះ ខាងកើតភ្នំលៀបនឹង ទៅផ្លូវនឹង ភ្នំស្រេះនឹង អាភ្នំលៀបនឹង អត់នៅជាប់ផ្លូវទេ ហើយអាភ្នំជញ្ជាំង អានឹងនៅជាប់ផ្លូវ នៅកន្លែងឆ្លាក់ថ្ម ឆ្លាក់ព្រះនឹង ។

ដានី ៖ អានឹងខាងព្រះនេត្រព្រះវិញ?

សឿន ៖ នឹងខាងព្រះនេត្រព្រះ មកដល់ព្រះនេត្រព្រះ នឹងមកលិច ។

ដានី ៖ ចុះភ្នំលៀប?

សឿន ៖ អានឹងចេញពីព្រះនេត្រព្រះទៅកើតទៅ បានភ្នំលៀបមួយតែឯង ហើយបៀតភ្នំលៀប មានភ្នំស្រេះ ។

ដារ៉ា ៖ កន្លែងនឹងដូចមានភ្នំ៣ ភ្នំលៀប ភ្នំ?

សឿន ៖ ភ្នំស្រេះ ។

ដារ៉ា ៖ ភ្នំអីមួយទៀតដែរ អ៊ំ?

សឿន ៖ ទេ! អាមួយទៀតភ្នំអីទេ ភ្លេចឈ្មោះអស់ ។

ដារ៉ា ៖ ដូចមានភ្នំមួយដែរ ភ្នំទ្រយោង?

សឿន ៖ អូ! នឹងហើយ ភ្នំជាប់បៀតភ្នំស្រេះ ។

ដារ៉ា ៖ មានភ្នំទ្រយោងមួយដែរ?

សឿន ៖ បាទ! បៀតភ្នំស្រែះ ។

ដារ៉ា ៖ ពីភ្នំលៀប និងភ្នំស្រែះនឹង វានៅចន្លោះនឹង?

សឿន ៖ ចន្លោះនឹង បាទ! ចន្លោះគ្នា ។

ដារ៉ា ៖ បើនិយាយទៅពីចំងាយប៉ុន្មានពីផ្ទះ យាយ ថែម?

សឿន ៖ ផ្ទះ យាយ ថែម គាត់នៅជើងភ្នំលៀបនឹង គិតទៅវាម៉ាគីឡូប្រហែលម៉ាគីឡូជាងដីនឹង នៅស្រែះប្រហែល២គីឡូ ៣គីឡូ ។

ដារ៉ា ៖ ចុះនៅតាមភ្នំនឹង គេធ្វើស្រែ ធ្វើចំការអីដែរ គេធ្វើដាំដុះអីដែរ អ៊ំ?

សឿន ៖ អ្នកនៅជើងភ្នំនឹង ធ្វើស្រែធ្វើអី ហើយនៅនឹងភ្នំនឹង គេដាំធ្វើបន្លែដាំអី ដាំត្រសក់ដាំអី ពេលខែវស្សាចឹង ដាំឪឡឹក ដាំត្រសក់អីលើនឹង ព្រោះដីវាដីធម្មតា ថ្មមួយៗមិនថ្មច្រើន ។

ដារ៉ា ៖ ចុះកន្លែងភ្នំត្រយោងនឹង គេដាំអីដែរ?

សឿន ៖ ដាំត្រសក់ដាំអីលើនឹង ។

ដារ៉ា ៖ ដាំត្រសក់ដាំអីដែរ?

សឿន ៖ ហ្នឹង! ដាំបន្លែហូបចិញ្ចឹមតាមសហករណ៍គេនឹង ។ ជើងភ្នំដាក់ដំឡូង ដាក់ត្រសក់ដាក់អីនឹង ។

ដានី ៖ អ៊ំខ្ញុំសុំសួរអ៊ំតិច ភ្នំលៀបនឹង យ៉ាងម៉េច ប្រជាជនរស់នៅ ក៏យ៉ាងម៉េច?

សឿន ៖ ភ្នំលៀបនេះ ប្រជាជនភូមិជុំវិញម៉ង ។

ដានី ៖ អូ! ភូមិជុំវិញ?

សឿន ៖ នោះហើយ សុទ្ធតែភូមិប្រជាជន មានផ្លូវព័ទ្ធជុំវិញ ។

ដានី ៖ ហើយចុះនឹង យាយ ថែម គាត់នៅនឹងដែរ?

សឿន ៖ នៅនឹងដែរ ។

ដានី ៖ នៅភ្នំលៀងនឹង?

សឿន ៖ បាទ! នៅនឹង ។

ដានី ៖ ចុះមន្ទីរស្រុកគាត់ធ្វើការៗនៅណា?

សឿន ៖ នៅនឹង ផ្ទះគាត់ ។

ដានី ៖ គាត់ធ្វើនៅផ្ទះគាត់ម៉ង?

សឿន ៖ បាទ! ផ្ទះធម្មតា ។

ដានី ៖ គាត់មិនមែនមកធ្វើការនៅជប់ នៅខាង?

សឿន ៖ អត់ទេ ។

ដានី ៈ ចុះភ្នំស្រេះ?

សឿន ៈ ភ្នំស្រេះមានតែប្រជាជនទេ ។

ដានី ៈ មានតែប្រជាជនទេ?

សឿន ៈ ហ្នឹង! មានប្រជាជន និងមានកងចល័តនៅធ្វើស្រែ ធ្វើអីនៅនឹង ។

ដានី ៈ មានប្រជាជន មានកងចល័ត?

សឿន ៈ បាទ!

ដានី ៈ តែកន្លែងនឹង មានដូចថាខាងកម្មាភិបាលអី គេនៅនឹងដែរអត់?

សឿន ៈ អានឹងគ្រាន់មានមេកង មេក្រុមអីនៅ ។

ដានី ៈ មេកង មេក្រុម?

សឿន ៈ បាទ! គេប្រធាន គេចាត់តាំងសហករណ៍នៅនឹងក្រុមៗម៉ាក្រុម តាមភូមិ មានភូមិគេចាត់តាំងក្រុមរបស់គេនៅនឹង ដើម្បីស្រណុកគេហៅធ្វើការ ។

ដានី ៈ ចុះភ្នំត្រយោង?

សឿន ៈ ត្រយោងក៏ប្រជាជននៅនឹងដែរ ។

ដានី ៈ ភ្នំត្រយោងនឹងប្រជាជននៅនឹង?

សឿន ៈ បាទ!

ដានី ៈ ចុះមានអីទៀត?

សឿន ៈ មានកងចល័ត ។

ដានី ៈ មានប្រជាជន មានកងចល័ត?

សឿន ៈ បាទ! កងចល័តក្នុងស្រុកនេះ ។

ដានី ៈ ចុះមានកន្លែងលុតដំគេដែរ អត់?

សឿន ៈ បាទ!

ដានី ៈ កន្លែងលុតដំ?

សឿន ៈ លុតដំ មាននៅជាប់គ្នានឹងដែរ ។

ដានី ៈ នៅកន្លែងលុតដំនៅជាប់នឹងភ្នំទ្រយោង?

សឿន ៈ បាទ! នៅជាប់មន្ទីរ ទើបរៀបចំបានប៉ុន្មានខែ ។ បានម៉ាខែជាងខ្ញុំៗទៅនៅព្រះនេត្រព្រះនឹង ។

ដានី ៈ ចុះអ៊ំអាចរៀបរាប់កន្លែងនឹងតិច ខ្ញុំចង់ដឹង ថាកន្លែងលុតដំនឹង ពីកន្លែងត្រឹមណាទៅកន្លែងណាភ្នំទ្រយោងនឹង?

សឿន ៖ អានឹងតាមពុកឹមអប់រំក្នុងស្រុកនឹង អ្នកខិលខូចអីអ្នកអី គេយកទៅដាក់នឹង តិចគេយកចេញវិញទៅ ក្នុងស្រុកនឹង គេអត់មានបញ្ជូនពីណាទៅ ។

ដានី ៖ ប៉ុន្តែទីតាំង កន្លែងនឹង កន្លែងភ្នំទ្រយោងនឹង កន្លែងលុតដំវាពី បើតាមអ៊ីចាំ ពីម្តុំត្រឹមណាទៅត្រឹមណាទៅ?

សឿន ៖ គិតកន្លែងនឹងតូចមិនធំ កាលនោះសុទ្ធតែប្រជាជន ដីប្រហែលជា១ហិចតា កន្លែងគេនឹង ២ហិចតា ។

ដានី ៖ ខ្ទង់ម៉ាហិចតា ២ហិចតា?

សឿន ៖ ហ្នឹងខ្ទង់២ហិចតា ខាងនោះប្រជាជន ទៅចល័ត ។

ដានី ៖ ខាងណាភ្នំទៅ?

សឿន ៖ នៅជាប់ភ្នំលៀបនឹងម៉ង នៅជើងភ្នំខាងជើង ជាប់ផ្លូវចេញពីភ្នំលៀបទៅនឹង ។

ដានី ៖ កន្លែងលុតដំនឹង នៅជាប់ភ្នំលៀប ឬភ្នំទ្រយោង?

សឿន ៖ ជាប់ទ្រយោង ប៉ុនវាគិតទៅភ្នំទ្រយោងគិតទៅមិនឆ្ងាយគ្នាប៉ុន្មាន វាភូមិជាប់គ្នារហូត សុទ្ធតែភូមិម៉ាដូរភូមិឃុំ ម៉ាឃុំ ភ្នំលៀបនឹង ។ នឹងក្នុងឃុំភ្នំលៀប ។

ដានី ៖ អ៊ីមានប្រសាសន៍មិញ ថាគេរៀបចំប្រហែលជាប៉ុន្មានខែ?

សឿន ៖ ប្រហែលខ្ទង់២ខែ ។

ដានី ៖ ប្រហែល២ខែ?

សឿន ៖ បាទ!

ដានី ៖ ពីណាគេអ្នករៀបចំ?

សឿន ៖ យាយ ចែម គាត់រៀបចំយកចល័តយកអីទៅដាក់នឹង ។ គាត់រៀបចំដូចថា មាននេះអី គាត់យកទៅអប់រំកន្លែងនឹង គណៈស្រុកគេរៀបចំ ។

ដារ៉ា ៖ រៀបចំបានប៉ុន្មានខែប៉ុន្មានឆ្នាំ បានវៀតណាមវ៉ៃចូលមក?

សឿន ៖ បាន២ខែ ។

ដារ៉ា ៖ បានតែ២ខែទេ?

សឿន ៖ បាទ! ប្រហែល២ខែដាង ចុះគិតមើលខែ ឆ្នាំ៧៨ខែ១១នឹង ចូលមកហើយ ខែ១១ ១២ ខែស្រូវទុំនឹង រៀបប្រូតនឹង គិតទៅមុននឹងខែ៨ ។

ដារ៉ា ៖ ខែ៨?

សឿន ៖ បាទ! ខែ៨ ។

ដារ៉ា ៖ អ៊ីចាំច្បាស់ណាស់ខែ៨?

សឿន ៖ នៅចឹងខ្ទង់ខែ៨ ។

ដារ៉ា ៖ ហើយមានអ្នកណាគ្រប់គ្រងកន្លែងនឹងដែរ?

សឿន ៖ មានប្រធានគេនៅនឹង ។

ដារ៉ា ៖ ប្រធានឈ្មោះអី ដែលអ៊ំ?

សឿន ៖ ប្រធានឈ្មោះ ពេទ្យ ។

ដារ៉ា ៖ បាទ?

សឿន ៖ ពេទ្យ ។

ដារ៉ា ៖ ឈ្មោះអីអ៊ំ?

សឿន ៖ ពេទ្យ ។

ដារ៉ា ៖ ពេទ្យ?

សឿន ៖ ហើយ យាយ ថែម នឹងម៉ង គាត់គ្រប់គ្រងលើនឹង ។

ដារ៉ា ៖ យាយ ថែម គាត់អ្នកគ្រប់គ្រងកន្លែងលុតដុំនឹង?

សឿន ៖ នឹងៗហៅអ្នកទៅនិយាយទៅ គាត់និយាយម៉េចៗអី ហើយអ្នកលុតដំកន្លែងនឹង គឺសហករណ៍ អ្នកបញ្ជូនមកទេ ។ ហ្នឹងឃើញសហករណ៍បញ្ជូន អត់ដែលឃើញត្រូវការអី មិនដែលឃើញ ពួកនឹងទៅទេ នៅចាំតែកន្លែង ដូចកងចល័តកងអី នៅចាំកន្លែងចល័តនៅរៀបចំនៅនឹង ។

ដារ៉ា ៖ កន្លែងលុតដំហ្នឹង គេហៅកន្លែងសន្តិសុខអីចឹង?

សឿន ៖ កន្លែងសន្តិសុខ ។

ដារ៉ា ៖ កន្លែងសន្តិសុខគេ?

សឿន ៖ បាទ! កន្លែង ។

ដារ៉ា ៖ កន្លែងភ្នំទ្រយោងនឹង?

សឿន ៖ បាទ! កន្លែងភ្នំទ្រយោងនឹង ។ នឹងកន្លែងសន្តិសុខគេ នគរបាលគេអ្នករៀបចំនឹង ។

ដារ៉ា ៖ ចឹងមានអ្នកគ្រប់គ្រងអីច្បាស់លាស់របស់គេទេ អ៊ំ កន្លែងសន្តិសុខ?

សឿន ៖ វាធម្មតា តែអ្នកចាត់តាំងវាច្បាស់លាស់នៅលើ យាយ ថែម ។

ដានី ៖ អូ! ចឹង?

សឿន ៖ ហ្នឹងហើយ ។ អ្នកនោះ គ្រាន់ដូចថា គ្នានៅចាំតែកន្លែង ហើយគេបញ្ជូនមកក៏ទទួលទៅៗគេ ថា ឥឡូវយើងមានការអី ក៏រាយការណ៍ឲ្យគេទៅ អ្នកនៅនឹង គ្នារាយការណ៍ឲ្យគេទៅ បើអត់ទេ ក៏គ្នាស្ងាត់ទៅ ។

ដានី ៖ ចុះបើតាមអ៊ំចាំ ដូចថាអ្នកដែល ដូចថាគាត់មានកំហុសអី គាត់បញ្ជូនតាមសហករណ៍អី អ៊ំចាំ

ថាប៉ុន្មានសហករណ៍ដែរ ដែលគេបញ្ជូនមកនឹង?

សឿន : ហ៉េ! ចាំមិនអត់ទេ មិនបានច្បាស់លាស់ទេ មិនចាំទេ ។

ដានី : មានប៉ុន្មានឃុំទៅ នៅក្នុងស្រុកព្រះនេត្រព្រះនឹង? មានឃុំភ្នំលៀប ឃុំ?

សឿន : មានភ្នំលៀប ព្រះនេត្រព្រះ ឃុំទៀនកាំ ។

ដានី : ឃុំទៀនកាំ?

សឿន : បាទ! ឃុំទឹកជោរ ឃុំប្រាសាទ ។

ដានី : ចុះឃុំរហាលមានទេ?

សឿន : អត់មាន ។

ដានី : អត់មានឃុំរហាលទេ? មានឃុំភ្នំលៀប ឃុំព្រះនេត្រព្រះ ឃុំទៀនកាំ ឃុំទឹកជោរ ឃុំប្រាសាទ ។

សឿន : ប្រាសាទ ដូចមានឃុំរហាលមួយ បន្ទាប់ពីព្រះនេត្រព្រះទៅ ៥-៦ឃុំ ។

ដានី : ចុះកាលនឹងអ៊ឹ អ្នកដែលត្រូវតាមសហករណ៍ដែលគេបញ្ជូនឲ្យមកលុតដីនឹង ប្រហែលជាប៉ុន្មានទៅ?

សឿន : មិនបានចាំអស់ទេ ។

ដានី : អត់បានចាំអស់ទេ?

សឿន : បាទ! អត់បានចាំអស់ទេ ឃើញមានទៅមនុស្សនៅធ្វើការរឹៗក្នុងនឹងទៅ ។

ដានី : ចុះកាលនឹង យាយ ថែម គាត់ខស្សហ៍ទៅកន្លែងសន្និសុខនឹងដែរ?

សឿន : គាត់ទៅ ពេលធ្វើការគ្រប់សហករណ៍ តែនេះ គាត់ដើរគ្រប់សហករណ៍ ។

ដានី : គាត់ដើរគ្រប់សហករណ៍?

សឿន : បាទ! គ្រប់សហករណ៍ គាត់ដើរមើល ធ្វើស្រែធ្វើអី តាមស្ទូងតាមអីនឹង កន្លែងប្រឡាយ គេឃើញគាត់ទៅ គាត់ដើរធ្វើប្រឡាយ ។

ដានី : គាត់ធ្វើប្រឡាយ?

សឿន : បាទ! នាំចល័តធ្វើប្រឡាយ ។

ដានី : គាត់មានដែលទៅមើលដូចថា អ្នកដែលត្រូវដូចថា សហករណ៍ចាប់បញ្ជូនទៅកន្លែងនឹង គាត់មានដែលទៅមើលអ្នកទោសដែលអត់?

សឿន : មិនដឹងម៉េច ឃើញតែគាត់ចេញចូល ។

ដានី : ឃើញគាត់ចេញចូលដែរ?

សឿន : បាទ! ចេញចូល ។

ដានី ៖ កាលនឹងគេមានធ្វើជាយ៉ាងម៉េច សម្រាប់ដាក់អ្នកដែលមានកំហុស អ្នកទោសនឹង គេធ្វើជារោងអីយ៉ាងម៉េច អ៊ំនៅចាំ?

សឿន ៖ រោងឃើញគេធ្វើវែងៗ ហើយមានផ្ទះបាយធំ ។

ដានី ៖ ធ្វើវែងៗយ៉ាងម៉េច?

សឿន ៖ បាទ! ធ្វើវែង ដូចថាធ្វើម៉ាខ្នង១០ម៉ែត្រ ៣-៤-៥ខ្នង ម៉ាខ្នង៣ម៉ែត្រក៏មាន ៤ម៉ែត្រក៏មាន តាមតូចតាមធំ ។ ហើយអាផ្ទះកងចល័តគេម៉ាខ្នងវែងនៅនឹងទៅ ។

ដានី ៖ ផ្ទះកងចល័តគេ មានផ្សេងទៀត?

សឿន ៖ ជាប់គ្នា នៅជាមួយគ្នានឹង ។

ដានី ៖ ចឹងសរុបទៅប្រហែលជាប៉ុន្មានទៅ?

សឿន ៖ សរុបផ្ទះហ៎?

ដានី ៖ សរុប ដូចថាអ្នកដែលនៅក្នុងនឹងម៉ង?

សឿន ៖ ចាំមិនអស់ទេ ។

ដានី ៖ បើតាមអ៊ំចាំ កាលនឹងកាលដូចថា សមាសភាពអ្នកដែលគេបញ្ជូនមកពីតាមសហករណ៍នឹងពួកគាត់ច្រើនខុសអីខ្លះទៅ?

សឿន ៖ ខ្លះដូចតែគ្នា អត់អីហូបគេចោទគ្នាទៅ លួចអីហូបតិចតួចនឹង ចេះចោទគ្នា យកគ្នាទៅ យកដល់នឹង ក៏គេតាមស្រាលតាមធ្ងន់ចឹងទៅ ។

ដានី ៖ តាមស្រាល តាមធ្ងន់ហ៎?

សឿន ៖ បាទ! តាមស្រាម តាមធ្ងន់ យើងនេះសំខាន់វាពិបាកអត់អីហូប ដល់នេះវាមិនសូវធ្វើការចឹង ដូចថាពេលទំនេរអីចឹង គេទៅណាអស់ គាត់រកអីហូបទៅ រកដំឡូងរកអីទៅ អំពៅអីទៅបេះហូបទៅ គេទាន់ក៏គេយកទៅៗ ។

ដានី ៖ ចុះមានអ្នកខុសអីផ្សេងទៀតដែរ ក្រៅពីអត់អីហូប លួចដូចថារបររបស់ហូបនឹង?

សឿន ៖ អត់ទេ ។ ទោសអីអត់មាននេះទេ ធ្ងន់អានឹងគេអត់មានយកទៅនឹងទេ ឃើញគេមិនដែលបញ្ជូនទៅនឹងទេ ។ ខ្ញុំទៅដល់ដូចមិនមានខបស័គ្គអីសូវច្រើនទេ គ្រាន់អ្នកខ្លះហូបខ្លះអីនឹងគ្នាទៅ ទាំងទោសនយោបាយ ទោសអីអត់មាន ។

ដានី ៖ ចុះអ៊ំអ្នកគ្រប់គ្រងនៅនឹងដែរ?

សឿន ៖ ហ្នឹងហើយ ខ្ញុំនៅចល័ត ។

ដានី ៖ គ្រប់គ្រងនៅ?

សឿន ៖ គ្រប់គ្រងតែកងចល័ត ។

ដានី :    គ្រប់គ្រងតែកងចល័តទេ?

សឿន : ហ្នឹងហើយ នាំគ្នាធ្វើប្រឡាយ ធ្វើស្រែប្រាំង ធ្វើអីនឹង ។ ធ្វើស្រែមិនទាន់បានម៉ាឆ្នាំផង ។

ដានី :    ចុះគ្រប់គ្រងអ្នកដែលមានកំហុសនៅនឹង?

សឿន : យាយ ចែម ។

ដានី :    យាយ ចែម អ្នកគ្រប់គ្រង?

សឿន : បាទ! ប្រធានមួយឈ្មោះ ពេទ្យ នៅនឹង ។

ដានី :    យាយ ចែម អ្នកគ្រប់គ្រង ហើយនឹងប្រធានមួយឈ្មោះ ពេទ្យ?

សឿន : ហ្នឹងហើយ គាត់នៅនឹង ប៉ុន្តែគាត់ យាយ ចែម គាត់ទៅមក ឃើញគាត់ទៅមកម្តងៗដែរ ។ ហើយមានកងសន្តិសុខគេនៅនឹង ។

ដានី :    មានកងសន្តិសុខគេទៀត?

សឿន : បាទ! នៅនឹង ។

ដានី :    កងសន្តិសុខ?

សឿន : កងសន្តិសុខស្រុកគេ យាយ ចែម ។

ដានី :    ប៉ុន្មាននាក់ទៅ?

សឿន : ដឹងប៉ុន្មាននាក់ទេ កម្លាំងនោះ ។

ដានី :    កងសន្តិសុខនឹង អ៊ំអ្នកជ្រើសរើស ហើយក៏ យាយ ចែម អ្នកជ្រើសរើស?

សឿន : យាយ ចែម អ្នកជ្រើសរើស ។

ដានី :    យាយ ចែម អ្នកជ្រើសរើសមក?

សឿន : បាទ! ដូចចល័តនៅចល័តដោយកងចល័ត វាគ្មានស្អីជ្រើសរើសចូលទេ ដល់គេចង់បញ្ជូលពីណាទៅណាអី អានឹងគេសម្រេចពីស្រុកទៅម៉ង ដកណាចេញ បញ្ជូលណាអី ។

ដានី :    ប៉ុន្តែ កាលនឹងកងចល័តនឹង នៅក្រោមគ្រប់គ្រងរបស់អ៊ំ?

សឿន : បាទ!

ដានី :    អ៊ំអ្នកគ្រប់គ្រង?

សឿន : បាទ! ចល័តមាន២០០នាក់ ចល័តស្រុក ។

ដានី :    ចល័តមាន២០០នាក់?

សឿន : ២០០នាក់ ។

ដានី :    ហ្នឹងក្រោមការគ្រប់គ្រងរបស់អ៊ំ ។ ចុះពួកសន្តិសុខ?

សឿន : ពួកសន្តិសុខ នឹងគ្រប់គ្រងលើ យាយ ចែម ហើយ ។

ដានី ៖ យាយ ថែម អ្នកគ្រប់គ្រង?

សឿន ៖ ហ្នឹងហើយគ្នាគេនឹង ។ ខ្ញុំអត់មានសន្តិសុខទេ ។

ដានី ៖ អត់មានសន្តិសុខទេ?

សឿន ៖ មានតែកងចល័តនឹង ការពារ ។

ដានី ៖ ចុះអ៊ំកាលនឹងស្គាល់ពួកសន្តិសុខដែរ? ក្រុមសន្តិសុខ អ៊ំមានស្គាល់?

សឿន ៖ ភ្លេចៗភ្លេចអស់ហើយ ។

ដានី ៖ ភ្លេចហើយ អ៊ំ?

សឿន ៖ បាទ! ភ្លេចឈ្មោះអស់ តែឃើញមុខក៏មិនស្គាល់ដែរ ។

ដានី ៖ ប៉ុន្តែកាលពីជំនាន់នឹង អ៊ំស្គាល់ដែរ?

សឿន ៖ អ្នកនៅរៀនជាមួយគ្នាក៏ភ្លេច ។ អ្នករៀនថ្នាក់ជាមួយគ្នានឹង កាលទៅលេងស្រុកនឹង ទៅដល់ ដល់គេនិយាយប្រាប់បានដឹង ។ អារៀននៅវត្តជាមួយគ្នា ស៊ីដេកជាមួយគ្នានឹង ។

ដារ៉ា ៖ មានទៅដល់កន្លែងនឹងដែរ?

សឿន ៖ បាទ! ទៅ ខ្ញុំទៅដល់ស្រុក ទៅធ្វើខ្សឿន ធ្វើអីជូនពុក ។

ដារ៉ា ៖ មានឈ្មោះអីខ្លះអ៊ំ ដែលថាទៅពីស្រុកអ៊ំដែរ ដែលទៅជួបគ្នានៅកន្លែងភ្នំទ្រយោង?

សឿន ៖ ហ៎! អត់ទេ ជួបស្រុកនោះ ។

ដារ៉ា ៖ ជួបស្រុក?

សឿន ៖ ហ្នឹងហើយ ។

ដារ៉ា ៖ កន្លែងមន្ទីរសន្តិសុខភ្នំទ្រយោងនឹង មានការគ្រប់គ្រងយ៉ាងម៉េច ស្អីយ៉ាងម៉េច អ៊ំជួយរៀបរាប់កន្លែងនឹងតិចមើល?

សឿន ៖ គ្រប់គ្រងៗធម្មតា ដូចថាយើង ដូចថាគេបញ្ជូនមកចឹង គ្នាអ្នកនៅនឹង គ្រាន់គ្រប់គ្រងមើល ធ្វើការ នាំគ្នាធ្វើការ ត្រូវឲ្យធ្វើអីៗ គេដឹកនាំគ្នាធ្វើទៅ ។ ដូចថាកងចល័តនឹង ថាថ្ងៃនេះត្រូវធ្វើអី ហ៎!ទៅវ៉ៃថ្ម ទៅកាស់ថ្ម ឬមួយទៅធ្វើស្រែ ទៅៗនាំគ្នាចេញទៅៗ ។

ដារ៉ា ៖ ចឹងអ្នកណាដាក់កិច្ចការ ដាការងារឲ្យធ្វើចេញពីណាមកវិញ?

សឿន ៖ យាយ ថែម គណៈស្រុកនៅនឹង ចេញពីគណៈស្រុកមកនឹង ចេញពីគណៈស្រុក ។

ដារ៉ា ៖ ចេញពី យាយ ថែម ទាំងអស់?

សឿន ៖ ចេញពីគណៈស្រុក ។

ដារ៉ា ៖ ចុះអ៊ំមានប្រសាសន៍មុននឹង ថាអ៊ំទទួលខាងចល័តចឹង?

សឿន ៖ បាទ!

ដារ៉ា ៖ ចល័តនៅភ្នំទ្រយោងនឹងម៉េង?

សឿន ៖ ហ្នឹង! ចល័តនឹងបោះទីតាំងនៅជិតគ្នានឹងឯង ជាប់គ្នា ។

ដានី ៖ ចល័តនឹង ជាចល័តយ៉ាងម៉េច ជាចល័ត?

សឿន ៖ គ្រាន់រៀបចំយុវជន យុវនារីប្រមូលផ្ដុំក្នុងម៉ាស្រុកមានម៉ាកងទៅ គេថាត្រូវការចាំបាច់កន្លែងណា គេដកកម្លាំងនឹងទៅធ្វើទៅ កន្លែងណាកុន(ទាល់) ដកទៅជួយធ្វើគ្នាកន្លែងនឹង ។ ហ៎! ត្រូវការទឹកបាក់កន្លែងណា ស្រែកន្លែងណា ហៅកម្លាំងនឹងទៅធ្វើម៉ាប្រឹប២-៣ថ្ងៃទៅ ចប់ ។

ដានី ៖ ហ្នឹងចល័តស្រុក?

សឿន ៖ បាទ! ចល័តស្រុក ។

ដានី ៖ ចល័តស្រុក ។ ចុះយុវជន យុវនារី ក្រោមការគ្រប់គ្រងរបស់អ៊ីនឹង គាត់ដូចថាជាយ៉ាងម៉េច គាត់មានសមាសភាពរបស់គាត់ដូចថា គាត់មានខុសឆ្គងត្រូវលុតដំដែរ ឬក៏យ៉ាងម៉េច?

សឿន ៖ អត់មានខុសឆ្គងអីទេ ការងារកាលណាគ្នាធ្វើដាក់ធ្វើ គ្នាធ្វើ អត់ដែលបញ្ជូនទៅណាទេ កងចល័ត ។

ដានី ៖ ចុះអ៊ីៗមានប្រសាសន៍មុននឹងមិញថា កាលនឹងអ្នកដែលខុស និងអ្នកទោសនឹង មានខ្លះធ្ងន់ខ្លះស្រាលអីចឹងនៅក្នុងកន្លែងភ្នំទ្រយោងនឹង?

សឿន ៖ មិនស្រាល ដូចខ្ញុំឮតាមសហករណ៍មក ដូចថាប្រធានភូមិថាមួយនោះថា ទៅលួចអីគេ ហើយម៉េចគេចាប់គេអីទៅ តដៃគេចឹងទៅ ធ្ងន់ ស្រាល យើងគេចាប់ វាតដៃគេ ។

ដានី ៖ ចុះអ្នកធ្ងន់គេដាក់យ៉ាងម៉េច អ្នកស្រាលគេដាក់យ៉ាងម៉េចទៅ?

សឿន ៖ កន្លែងដាក់នឹង ម៉េចធ្វើជារោងនៅជាប់គ្នា កន្លែងចល័តនៅចល័ត មិនសូវចូលកន្លែងទេ ។

ដានី ៖ ចឹងបានន័យថា?

សឿន ៖ មិនដូចលក់ដូរ យើងចេញចូលទៅវិញ ។

ដានី ៖ អ្នកធ្ងន់គេដាក់ដោយឡែក អ្នកស្រាលគេដាក់ដោយឡែក?

សឿន ៖ បាទ! សុទ្ធតែមានកន្លែងគេដាក់ ។

ដានី ៖ ចុះដូចថាអ្នក?

សឿន ៖ ប៉ុនសុទ្ធតែរោងគេ ធ្វើជារោងគេស្រោប់លើកជាខ្ទង់ៗ ម៉ាខ្ទង់៣ម៉ែត្រ៤ម៉ែត្រ៤ជ្រុងចឹងទៅ ឃើញខ្ទង់តែមួយវែង បាន៧-៨ម៉ែត្រ ៣បន្ទប់ ។

ដានី ៖ ចុះអ៊ីអ្នកដែលធ្ងន់ គេមានដាក់ខ្នោះ ដាក់អីដែរអត់?

សឿន ៖ ដូចអត់ គ្រាន់គេយាមតាម ឃើញកម្លាំងនគរបាលតាមនឹង តែចូលបន្ទប់ទៅដេក ពេលធ្វើការគេនាំជូនទៅធ្វើការទៅ ។

ដានី ៖ គេនាំជូនទៅធ្វើការ?

សឿន ៖ នាំជូនទៅធ្វើការ ឃើញនាំដើរកាត់ទៅ ទៅវ៉ៃថ្មវ៉ៃអី កម្លាំងគេដូចថាទៅប៉ុន្មាននាក់ ១០នាក់ចឹង គេទៅគ្នា៣-៤នាក់ចឹង ទៅតាមទៅធ្វើការកន្លែងនឹង ។ ទៅស្ទូង គេនាំទៅធ្វើចឹង ។

ដានី ៖ ចុះអ្នកស្រាល អ្នកដែលកំហុសស្រាល គេយ៉ាងម៉េច?

សឿន ៖ ស្រាល ឃើញគេមិនសូវតាម ។

ដានី ៖ គេមិនសូវតាម?

សឿន ៖ ហ្នឹង ។

ដានី ៖ គេឲ្យធ្វើការយ៉ាងម៉េចដែរ?

សឿន ៖ ធម្មតា ដូចគ្នាចឹង ។

ដានី ៖ ធ្វើការធម្មតា?

សឿន ៖ ហ្នឹង! ត្រូវការវ៉ៃថ្មៗ ត្រូវការស្ទូងៗ ត្រូវការលើកទំនប់ទៅលើកទំនប់ ។

ដានី ៖ ធ្វើការជាមួយកងចល័តរបស់អីដែរ?

សឿន ៖ បាទ! ធ្វើការដូចគ្នានឹង ។

ដានី ៖ ចុះអីកាលនឹង ខ្ញុំអត់ទាន់ច្បាស់ត្រង់ជាអ្នកគ្រប់គ្រងៗ មិញអីមានប្រសាសន៍ថា អ្នកគ្រប់គ្រងចល័តដង មានអ្នកគ្រប់គ្រងនៅកន្លែងមន្ទីរសន្តិសុខនឹងផ្សេង?

សឿន ៖ បាទ! ផ្សេងគ្នា ។

ដានី ៖ ប្តូក៏ប្រធាន អនុប្រធានអី?

សឿន ៖ អត់ផ្សេងគ្នា ។

ដានី ៖ ផ្សេងគ្នាម៉ង?

សឿន ៖ បាទ! ផ្សេងគ្នា គេទៅនៅ ។

ដានី ៖ ចឹងអីប្រធានចល័តស្រុក?

សឿន ៖ ហ្នឹងហើយ គ្រប់គ្រងចល័តស្រុក ។

ដានី ៖ គ្រប់គ្រងចល័តស្រុក?

សឿន ៖ បាទ!

ដានី ៖ ចុះអនុអី?

សឿន ៖ អត់មាន ។

ដានី ៖ អត់មានអនុទេ?

សឿន ៖ ប៉ុនមានមេក្រុមមេកង តាមកងគេ ។

ដានី ៖ មានមេក្រុមតាមកង?

សឿន ៖ ម៉ាកងៗគេ ដូចថា១០នាក់ចឹងម៉ាក្រុមចឹងទៅ មានមេក្រុមគេ ៥០នាក់ម៉ាកង ៣ក្រុមម៉ាកងចឹងទៅ ។

ដានី ៖ ចុះអ្នកដែលគ្រប់គ្រងនៅមន្ទីរសន្តិសុខឈ្មោះ?

សឿន ៖ ឈ្មោះ ពេទ្យ ។

ដានី ៖ ឈ្មោះ ពេទ្យ?

សឿន ៖ បាទ!

ដានី ៖ ឈ្មោះ ពេទ្យ គាត់អ្នកស្រុកណាដែរ?

សឿន ៖ គាត់អ្នកកំពត ។

ដានី ៖ សព្វថ្ងៃ គាត់នៅណាដែរ?

សឿន ៖ ថាស្លាប់បាត់ហើយ ដូចបាត់ឈ្មោះសូន្យ ដូចស្លាប់បាត់ ។

ដានី ៖ ចុះប្រពន្ធគាត់?

សឿន ៖ ប្រពន្ធគាត់ដឹងម៉េច ។

ដានី ៖ ស្គាល់ប្រពន្ធគាត់?

សឿន ៖ អត់ស្គាល់ បើបែកគ្នារហូតមកពេលរត់ចេញ ។ ចុះនៅនឹងបានតែ២ខែ បែកគ្នានឹងក៏ចេញយួនបុកមករត់ចេញម៉ង ។ ចេញមកខ្ញុំចេញពីនឹងទៅដងរែកទៅ ។ ទៅនៅដងរែក ។

ដានី ៖ ចុះអ៊ឹបន្ទាប់ពីពេទ្យមក មានពីណាឈ្មោះអីទៀត?

សឿន ៖ ដូចអត់ ។ មានមេក្រុមនគរបាលគេ កងគេ តាមក្រុមៗគេនឹង នៅម៉ាក្រុមៗគេ ។

ដានី ៖ អ៊ំនៅចាំឈ្មោះពីណា ដែលថាជានៅក្រុមៗ?

សឿន ៖ ដូចវាភ្លេចអស់ហើយ ភ្លេចឈ្មោះអស់ ។

ដានី ៖ ចឹងអ្នកដែលគ្រប់គ្រងទៅលើក្រុម?

សឿន ៖ ដែលនៅកងចល័តជាមួយខ្ញុំឥឡូវនឹងក៏ភ្លេច ដូចអត់នឹកចាប់អារម្មណ៍ទៅ បែកគ្នាទៅសល់ៗភ្លេចឈ្មោះគេទៅ ។

ដារ៉ា ៖ ពូស្គាល់ពូសំផាត់ទេ?

ដានី ៖ ពូផាត់? ពូផាត់គាត់នៅព្រះនេត្រព្រះ សព្វថ្ងៃ គាត់នៅភូមិកណ្ដាល ។

សឿន ៖ វាភ្លេចឈ្មោះអស់ បើឃើញមុខទៅវាចេះតែ ។

ដារ៉ា ៖ ពេលដែលពួកខ្ញុំបានជួបគាត់ គាត់ថាចង់ជួបអ៊ំដែរ បើសិនជាបានឃើញបានអី គាត់ថាអ៊ំបាន ដូចជាជួយគាត់អីចឹង ។

សឿន ៖ បើភ្លេចឈ្មោះ ។

ដារ៉ា ៖ ជួយឲ្យបានរស់រានមានជីវិតដល់រាល់ថ្ងៃអីចឹងអ៊ំ ។ នឹកគិតមើល អាចនឹកឃើញទេ ពូសំដាត់ពេលប្រាប់ថាពូសំដាត់ចឹង អ៊ំប្រហែលជាអាចចាំហើយ?

សឿន ៖ ចាំនឹកមិនឃើញទេ ឃើញមុខអានឹងចេះប្រហែលៗ ហើយមួយនៅភ្លេចឈ្មោះវាទៀត វាមកលក់ជ្រូកលក់អីនេះ ឃើញវាៗអត់ស្គាល់ទេ ស្គាល់ខ្ញុំ ។

ដានី ៖ គាត់ធ្វើអី អ្នកលក់ជ្រូកនឹង?

សឿន ៖ ហ្នឹង គាត់ដើរជួញលក់ជ្រូក លក់អី ។

ដានី ៖ ប៉ុន្តែ គាត់យ៉ាងម៉េចដែរ?

សឿន ៖ នៅកងចល័តជាមួយគ្នានឹង ។

ដានី ៖ កងចល័តជាមួយអ៊ំដែរ?

សឿន ៖ ហើយគាត់ ចុះសម័យនេះ គេចេះរកស៊ីដែរ គេលក់ គេចេញជិកម៉ូតូ ជិកអី ។

ដានី ៖ ចុះអ៊ំមានប្រសាសន៍មុនមិញថា ខាងសន្តិសុខ ខាងនគរបាលនឹង យាយ ចែម គាត់អ្នកគ្រប់គ្រងផ្ទាល់?

សឿន ៖ បាទ! គាត់អ្នករៀបចំ ចាត់ចែងនឹង លើស្រុកទាំងអស់ ។

ដានី ៖ លើកស្រុកទាំងអស់?

សឿន ៖ ចល័ត នគរបាលអីលើស្រុកទាំងអស់ ។ ចាត់តាំងឃុំអី តាមឃុំ សារនឹង ទៅពីលើទៅទៀតទៅតៗគ្នាទៅណា ។ អ្នកណាការងារយើងនៅត្រឹមប៉ុន្មាន យើងដឹងថាត្រឹមការងារយើង ។ យើងទៅដឹងដល់ការងាររបស់គេ ។ គេឲ្យធ្វើអីធ្វើនឹងទៅ ។

ដានី ៖ មន្ទីរសន្តិសុខនឹង យាយ ចែម គាត់អ្នកបង្កើតនៅឆ្នាំ អី!នៅខែ?

សឿន ៖ មើលបង្កើត គិតទៅ ទើបបាន២ខែ គាត់បង្កើតទៅនៅនឹង គាត់បង្កើត ។

ដានី ៖ គាត់បង្កើតទើបបាន២ខែ?

សឿន ៖ បាទ! ២ខែ ក៏កើតរឿងរ៉ាវចឹងទៅ រត់ប្រាសអាយុរៀងខ្លួន ។

ដានី ៖ អ៊ំដូចថាជិតស្និតជាមួយគាត់ដែរ?

សឿន ៖ បាទ?

ដានី ៖ ជិតស្និតជាមួយគាត់ ដូចថាយើងស្គាល់ រាក់ទាក់ ទៅស្និតស្នាល?

សឿន ៖ នៅមេក្រុមចឹង យើងទៅទាក់ទងអី នៅក្នុងនឹងរហូត ដូចស្បៀងអាហារអី យើងទាក់ទង ។

ដានី ៖ យើងទាក់ទងជាមួយគាត់?

សឿន ៖ នឹង ទាក់ទងជាមួយនិរសាគាត់ ។

ដានី ៖ និរសាគាត់ឈ្មោះអី?

សឿន ៖ ហ៊ឺ! ក្មួយអាមួយនឹងឈ្មោះ ពុកវ៉ាទៅកាន់បញ្ជីនឹង ។

ដានី ៖ បាទ?

សឿន ៖ វ៉ាទៅ...ក្មួយឈ្មោះ ។ អាមួយ អាសុខ កាលណាយើងនេះ ខុះខាតយើងឡើងទៅ ទាក់ទង នៅមន្ទីរគេ ដូចខុះអង្ករខុះម្ហូបអី ឡើងដល់មន្ទីរ ។ មានការណ៍អីគេទាក់ទងកន្លែងនឹង មកគេ ហៅយើងទៅធ្វើថាឥឡូវយកកម្លាំងទៅនេះ ប៉ុន្មាន២០នាក់ ៣០នាក់ ឬមួយកម្លាំងត្រូវដក ចេញពីនឹងទៅធ្វើប្រឡាយនេះ ឬមួយថាឥឡូវទៅជួយស្ទូងភូមិនេះឃុំនេះ ចឹងទៅសំខាន់ៗ ។

ដានី ៖ ចុះអ៊ំកាលនឹង ដូចថាការហូបចុកអីយ៉ាងម៉េចដែរ ដូចថាអ៊ំនៅខាងកងចល័ត ឬក៏ខាងអ្នក ទោស?

សឿន ៖ ខាងកងចល័តកាលនឹងហូបបបរទាំងអស់គ្នា ។ ហើយយើងហូបតែបាយតែយើង ក៏គេថា កាលណាកងចល័តហូបអី យើងហូបនឹងជាមួយគ្នាទៅ បបរ ។

ដានី ៖ កាលនឹងអ៊ំហូបបបរដែរ?

សឿន ៖ បបរ ។

ដានី ៖ បបរយ៉ាងម៉េច អ៊ំអាចរៀបរាប់?

សឿន ៖ បបរសធម្មតាយើងនឹង បានម្នាក់២ចាន ។

ដានី ៖ ដូចថាក្នុងម្នាក់ បើយើងគិតជាអង្ករវិញ អាចថាបានប៉ុន្មានទៅ?

សឿន ៖ ហ៊ឺ! បបរ១០០នាក់ វ៉ាដាក់អង្ករ៣០-៤០កំប៉ុង ហើយបបរទៅ បបរដាក់ឆ្នាំងចាក់ទៅ កូរទៅ ថ្ងៃត្រង់ ថ្ងៃល្ងាចនឹង ២ពេល ។

ដានី ៖ ហើយហូបឆ្អែតទេ អ៊ំ?

សឿន ៖ ហូប ថ្ងៃណាអត់ឆ្អែត អត់ទៅ ថ្ងៃណារៀងមិនសូវហេវ ក៏ឆ្អែតទៅ២ចាន ។

ដានី ៖ ២ចាននឹង យើងហូបតែពេលថ្ងៃត្រង់ ហើយនឹងល្ងាច?

សឿន ៖ បាទ! ពេលថ្ងៃត្រង់ និង ពេលល្ងាច ។

ដានី ៖ ពេលព្រឹក?

សឿន ៖ ពេលព្រឹកអត់មានអីទេ ព្រលឹមឡើងចេញធ្វើការ ។

ដានី ៖ ២ចានប៉ុនៗណា ចាននឹង?

សឿន ៖ ចានៗកូមយើងធម្មតា ។

ដានី ៖ ចានតូចៗ?

សឿន ៖ ហ៊ឺ! មិនតូចដែរ ធំដែរ ។

ដានី ៖ ប៉ុនបានចង្កើះយើងរាល់ថ្ងៃ?

សឿន ៖ ហ៊ឺ! មិនប៉ុននឹងទេ ធំជាងនឹង អត់ដែលឃើញបានចង្កើះ ឃើញអាបានកូមជ្រុង១តិច ។

ដារ៉ា ៖ ហ្នឹងសម្រាប់របបហូបចុករបស់កងចល័តកងអី ឬក៏របស់ប្រជាជនដែលនៅ?

សឿន ៖ ទាំងអស់គ្នា ប្រជាជនអីក៏ដូចគ្នាដែរ បើតាមមើល តាមសហករណ៍ចេះ នឹងហូបដូចគ្នាទាំងអស់ព្រោះវាអស់ស្រូវហើយ ។ បានខ្ញុំទៅដល់ត្រូវទឹកលិចទៀត កាលឆ្នាំ៧៨នឹង ។ ទៅដល់ទឹកលិចឡើងអស់ស្រូវម៉ាជួរមុខព្រះនេត្រព្រះនឹងសុទ្ធតែទឹកទាំងអស់ ។ ម៉ាជួរមុខភ្នំលៀបនឹងមើលទៅលើសុទ្ធតែទឹក១ត្រឹម-ក១ តាមផ្លូវចេញពីភូមិរំដួល ចេញពីនេះលើភូមិរំដួលទៅដើងទៅភ្នំស្រុក តាមផ្លូវសុទ្ធតែទឹកទាំងអស់ ។ ហើយកងចល័តខ្ញុំទៅលើពេលដែលទឹកឡើងទឹកលើក ឡើងទៅកាយទំនប់ ទប់ស្រែនេះមួយនោះមួយ កុំឲ្យវាចូល ប៉ុនទប់ម៉េចឈ្នះ ទឹកឡើងមកហើយ ។

ដានី ៖ អ៊ំកាលនឹង ដឹងថាអ្នកទោសក្នុងនឹង គេឲ្យហូបដូចកងចល័ត ឬក៏ខុសគ្នា?

សឿន ៖ ដូចគ្នា ។

ដានី ៖ ម៉េចបានអ៊ំដឹងដូចគ្នា?

សឿន ៖ ឃើញ ខ្ញុំដើរទៅឃើញគេបបរដូចគ្នានឹង សុទ្ធមានឆ្នាំងបបរដូចគ្នា ។

ដានី ៖ ហូបបបរជាមួយម្ហូបអីទៅ?

សឿន ៖ បបរជាមួយសម្ល១បន្លែនេះ បន្លែនោះតាមយើងមានត្រកួនល្ពៅចឹងទៅ យើងរកបានបន្លែអីយើងស្ល ក្រុមណាសហករណ៍ណាគេរកបន្លែអី ។ បើសហករណ៍ គេមានបន្លែគេច្រើន គេមានចេក គេមានល្ពៅ តាមភូមិគេ បើតាមកងចល័តកងអី យើងដើរសុំគេ ឬមួយស្នើទៅស្រុកទៅ បាន១បន្លែមកស្លហូបទៅ ។

ដានី ៖ កាលនឹងហូបជាមួយសម្ល១ មានតែបន្លែទេ អត់មាន ចុះត្រី សាច់អី?

សឿន ៖ មាន១ ត្រី សាច់ ។

ដានី ៖ ត្រី សាច់ យើងបានមកពីណា?

សឿន ៖ ត្រី សាច់ ដូចថាក្នុងកងចល័ត យើងរៀបចំ៣នាក់ ៤នាក់រកត្រី គេរៀបចំចឹង ។ ហើយកន្លែងគេមួយ១ សហករណ៍មួយ១ក៏ចឹងដែរ គេរៀបចំកម្លាំងគេរកត្រីចឹងទៅ នៅកន្លែងនឹងបើគេរៀបចំកម្លាំងគេទៅរកត្រី ។ បើគេរកបានគេបញ្ជូនមកកងគេ ។

ដានី ៖ ចុះអ៊ំរបៀបដូចថាការហូបចុក ហូបបបរអីនឹង ពីណាគេអ្នកចាត់ចែង ឲ្យយើងថាយើងត្រូវហូបយ៉ាងម៉េច អ្នកដែលថា?

សឿន ៖ គឺ ទៅដល់ត្រូវអស់អង្ករ អត់មានស្រូវ មានអី ដល់ហើយយើងថ្លៃតាមនឹង បើមានអង្ករ

ចេះដាំហូប បើអត់អង្ករយើងដាំថ្ងៃនឹង អត់ឆ្អែក ដូចកងចល័តចឹង កាលណាយើងរូតយក ដាំបាយ រឹងពេក អត់អីហូបហើយ ឆ្អែតទៅ ។

ដានី ៖ យើងច្នៃតាមកង តាម?

សឿន ៖ ហើយគេបញ្ជាមកពីលើក៏ចឹងដែរ ។

ដានី ៖ បញ្ជាពីណាមក?

សឿន ៖ តាមស្រុកតាមអីមក គេថាឥឡូវយើងហូបបបរសិន ។

ដានី ៖ យាយ ថែម?

សឿន ៖ ហ្នឹងហើយ តាមស្រុកតាមមន្ទីរ ។

ដានី ៖ យាយ ថែម គាត់បញ្ជាឲ្យហូបបបរ?

សឿន ៖ ហ្នឹងហូបបបរ ព្រោះយើងអស់ស្រូវ អស់អីហើយ អត់មានអង្ករ ។

ដានី ៖ ចុះអ៊ំខសប្បាហ៍ទៅប្រជុំជាមួយ យាយ ថែម ទេ? ទៅប្រជុំរឿងផែនការ ទៅប្រជុំរឿង សភាពការណ៍អី?

សឿន ៖ ខ្ញុំនៅកងចល័ត ខ្ញុំទៅប្រជុំជាមួយគាត់២ដង ពេលនឹងផែនការដូចថាត្រូវដកចល័តទៅធ្វើអី ណា ដកកម្លាំងទៅធ្វើអីណា គាត់ឲ្យនិរសាមកប្រាប់ម៉ង ថាឲ្យដកទៅនេះ ដកទៅនោះ ។

ដានី ៖ ដកទៅណាទៅ?

សឿន ៖ ទៅធ្វើការតាមឃុំតាមអី ទៅជួយធ្វើស្ទូង តាមភូមិ តាមឃុំ ឬមួយលើកទំនប់កន្លែងណាត្រូវ ដាច់អី ដកកម្លាំងទៅជួយម៉ាប្រឹសទៅជួយគ្នាទៅ ។ ហើយសល់ពីនឹង យើងធ្វើការរបស់ យើងសិនទៅ ដាំបន្លែដាំអីខ្លះទៅ ដាំស្ពៃ ដាំអីត្រសក់អីហូប ហើយកម្លាំងមួយចំនួនរកត្រី រកម្ហូបទៅ ។

ដានី ៖ ចុះអ៊ំអានឹង ប្រជុំជាមួយគាត់ម្ដងទៀត ធ្វើអីទៅ គាត់ប្រជុំយ៉ាងម៉េច?

សឿន ៖ គាត់ទៅប្រជុំរឿងលើកផែនការការងារ ។

ដានី ៖ តែប្រជុំរឿងលើកផែនការ?

សឿន ៖ ផែនការការងារ យើងត្រូវធ្វើអី ដើម្បីដោះស្រាយជីវភាពយើង យើងត្រូវរៀបចំកម្លាំង រកត្រីរកអីឲ្យស្រួល ដើម្បីឲ្យវាខ្វះខាត ។

ដានី ៖ ចុះអ៊ំពេលដែលយួនជិតចូលមក យាយថែម មានហៅប្រជុំដែលអត់?

សឿន ៖ អត់ទេ អត់ទាន់មានប្រជុំផង ស្រាប់លេងវៃមកហើយ ស្រាប់ដល់សៀមរាបហើយ ។ ដល់ សៀមរាបក៏នាំគ្នារៀបចំអីវ៉ាន់ចេញទៅ ។

ដានី ៖ អ៊ំកាលនឹង យាយ ថែម គាត់គណៈស្រុកចឹង?

សឿន ៖ បាទ!

ដានី ៖ ចុះអនុគាត់មានទេ?

សឿន ៖ ប្ដី ប្រពន្ធគាត់ ។

ដានី ៖ ប្ដីប្រពន្ធគាត់?

សឿន ៖ ហ្នឹង តា ញ៉ែន នឹង ។

ដានី ៖ តា ញ៉ែន គាត់ធ្វើអី?

សឿន ៖ ស្រុកដែរនឹង ។

ដានី ៖ ស្រុកណា?

សឿន ៖ ស្រុកនឹង ជាមួយគ្នានឹង ។

ដានី ៖ យាយ ចែម គាត់ធ្វើ?

សឿន ៖ ប្រធាន ។

ដានី ៖ ប្រធាន ចុះ?

សឿន ៖ ប្ដីគាត់ធ្វើអនុ ជាមួយគ្នានឹង ។

ដានី ៖ ចុះខាងឃុំ ដូចជាខាងឃុំភ្នំលៀបអីពីណាគេ?

សឿន ៖ ឃុំភ្នំលៀបនឹង អានឹងកម្លាំងចាត់តាំង គាត់នាំមកនឹង ។

ដានី ៖ ឈ្មោះអី អឹចាំទេ ពីណាគេ?

សឿន ៖ នៅប្រាសាទឈ្មោះ ហ៊ូវ ។

ដានី ៖ នៅប្រាសាទឈ្មោះ ហ៊ូវ?

សឿន ៖ ហ្នឹងហើយ ។

ដានី ៖ ហើយឥឡូវគាត់នៅណាដែរ?

សឿន ៖ ដឹងវានៅណាទេ ឥឡូវនឹង ចាប់ដកស្ងួង អត់ដឹងវានៅណា អត់ទេ ។

ដានី ៖ អត់ដឹងគាត់នៅណា?

សឿន ៖ អត់ដឹងគាត់នៅណា ។

ដានី ៖ ចុះឃុំភ្នំលៀប?

សឿន ៖ ឃុំភ្នំលៀប អាកាន់ ។

ដានី ៖ ឈ្មោះ កាន់?

សឿន ៖ បាទ!

ដានី ៖ កាន់ គាត់នៅណាដែរ?

សឿន ៖ គាត់នៅស្រុកនោះ ប៉ុនដឹងស្លាប់នៅបើបែកគ្នាយូរ ។

ដានី ៖ គាត់នៅស្រុកជាមួយអ៊ីដែរ?

សឿន ៖ បាទ! ភូមិខុសគ្នា ។

ដានី ៖ នៅភូមិអីទៅ?

សឿន ៖ នៅភូមិព្រៃកគ្គី ។

ដានី ៖ នៅភូមិព្រៃកគ្គី គាត់ឈ្មោះ កាន់?

សឿន ៖ បាទ!

ដានី ៖ ភូមិព្រៃកគ្គី គាត់ឈ្មោះ កាន់ ប៉ុន្តែពេលបែកទៅ គាត់ទៅនៅស្រុកវិញ?

សឿន ៖ បាទ!

ដានី ៖ ប៉ុន្តែពេលបែកវិញ គាត់ទៅនៅស្រុកវិញ?

សឿន ៖ បាទ!

ដានី ៖ ឥឡូវគាត់ប្រើឈ្មោះ កាន់ ដដែល ហើយម៉េច?

សឿន ៖ ដឹងម៉េច បើបែកគ្នារហូតមក ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអីដែរ?

សឿន ៖ ប្រពន្ធឈ្មោះ ហ៊ីម ។

ដានី ៖ ប្រពន្ធឈ្មោះ ហ៊ីម ។ នៅភូមិព្រៃគ្គី?

សឿន ៖ ព្រៃគ្គី ។

ដានី ៖ ព្រៃគ្គី ឃុំត្រពាំងធំ?

សឿន ៖ បាទ!

ដានី ៖ ចុះឃុំរហាល?

សឿន ៖ ឃុំរហាល តា ណុប ។ ប៉ុន តា ណុប ឥឡូវមិនដឹង គាត់នៅណា ។

ដានី ៖ អត់ដឹងគាត់នៅណា?

សឿន ៖ បាទ! អត់ដឹងគាត់នៅណា ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអី តា ណុប?

សឿន ៖ ប្រពន្ធ ដឹងឈ្មោះអី ។

ដារ៉ា ៖ អ៊ំ យាយ ចែម កាលដែលគាត់នៅភ្នំទ្រយោង នៅភ្នំលៀបនឹង ថាដូចគាត់កាលនឹងមានផ្ទៃពោះផងកាលនឹង អ៊ំហេ៎?

សឿន ៖ កាលនឹង គេដឹងម៉េចទេដូចមិនសូវឃើញ ដូចអត់មានឃើញផ្ទៃពោះទេ បើមើល ។

ដារ៉ា ៖ ព្រោះអ៊ំ មានប្រសាសន៍ពីខាងដើម ថាកន្លែងភ្នំទ្រយោងនឹងជាសន្តិសុខនឹង រៀបចំប្រហែល ជាបានប្រហែលជាខែ៨ ឆ្នាំ៧៨ ចឹងអ៊ំ?

សឿន ៖ ២ខែ ។

ដារ៉ា ៖ ២ខែ វៀតណាមចូល?

សឿន ៖ ហ្នឹងវៀតណាមចូល ។

ដារ៉ា ៖ ហើយពេលរត់នឹង អ៊ំរត់ទៅជាមួយ យាយ ចែម ទៅដែរ?

សឿន ៖ រត់គេទៅមុនខ្ញុំៗទៅក្រោយៗ ក៏ជួបគ្នានៅដងរែក ជួបគ្នាក៏គាត់អត់ឃើញមានកូនមានចៅ កូនគាត់មានមួយជាប់យូរហើយ ធំដែរ ។

ដារ៉ា ៖ គេថាពេលដែលវៀតណាមចូលមក រត់នឹងគាត់មានកូនខ្ចីកូនអីឆ្លងទន្លេតាមផ្លូវ?

សឿន ៖ បាទ! ដែលបែកគ្នារហូត ដល់ពេលរត់មកបានតិចបែកគ្នាមក ខ្ញុំមកតែខ្ញុំ ។

ដារ៉ា ៖ ចឹងពេលវៀតណាមចូលមកនឹង ពេលទ័ពរណសិរ្សចូលមក យាយចែមរត់ទៅមុន?

សឿន ៖ ហ្នឹងចេញមុនក្រោយ ខ្ញុំទៅតាមក្រោយទៅ ។

ដារ៉ា ៖ អ៊ំប្រហែលជារយៈពេលប៉ុន្មានៗថ្ងៃ ប៉ុន្មានអីដែលអ៊ំ?

សឿន ៖ ទៅ បានជួបគ្នាបានប្រហែលម៉ាខែ ខ្ញុំបែកគ្នាទៀតទៅ ។

ដារ៉ា ៖ អត់ទេ កន្លែងភ្នំទ្រយោង?

សឿន ៖ ហ្នឹង ខ្ញុំចេញពីភ្នំទ្រយោងនឹងទៅ បានម៉ាខែទៅជួបគ្នា គាត់បាន៤-១០ថ្ងៃជាមួយ យាយ ចែម នឹង ខ្ញុំបែកគ្នាទៀតទៅ ។ ខ្ញុំក៏ចេញទៅត្បូងទៀតទៅ គាត់នៅដងរែក ។ ខ្ញុំចេញមក នៅព្រៃមាន់ហើយ ។

ដានី ៖ មកខាងព្រៃមាន់?

សឿន ៖ បាទ! មកខាងព្រៃមាន់ ។

ដារ៉ា ៖ តែខ្ញុំចង់សួរបញ្ជាក់អ៊ំពីកន្លែងភ្នំទ្រយោងនឹង កន្លែងភ្នំល្មៀបនឹង ពេលវៀតណាមចូលមក ទ័ពរណសិរ្សចូលមក យាយ ចែម មិនរត់ភៀសខ្លួនទៅ?

សឿន ៖ បាទ! ទៅដើរ ។

ដារ៉ា ៖ ទៅដើរ ។ ហើយពេលរត់ភៀស?

សឿន ៖ ហើយខ្ញុំក៏ទៅតាមក្រោយ ។

ដារ៉ា ៖ ទៅតាមក្រោយ ហើយខ្ញុំសួរចន្លោះនឹង វាប៉ុន្មានថ្ងៃដែលយាយចែមចេញទៅមុនប៉ុន្មានថ្ងៃ បានអ៊ំចេញទៅតាមក្រោយ?

សឿន ៖ ម៉ាល្ងាច គេទៅពេលព្រឹក ខ្ញុំទៅថ្ងៃល្ងាចចេញហើយ ។ ថ្ងៃល្ងាចអី ខ្ទង់ម៉ោង១ខ្ញុំចេញ

ព្រោះ មកដល់ស្ពានតាប៉ុន ខ្ញុំចេញទៅ។ ចេញបានដឹង គេចេញទៅមុនអស់។

ដាវ៉ា : ចុះមានអ្នកនៅព្រះនេត្រព្រះនឹង គេស្គាល់អ៊ំច្រើនទេ ពេលដែលអ៊ំដឹកនាំចល័តពេលនឹង?

សឿន : ដឹងគេភ្លេចអត់ នៅមានចាំ បើកងចល័តស្គាល់ខ្ញុំដែរ ឃើញនៅភ្នំស្រុកវ៉ាន់ ស្គាល់គ្នាធ្លាប់មកលេង កាលខ្ញុំនៅធ្វើនៅព្រៃមាន់នោះ គ្នាមកលេងអី គេយកនំយកអីមកផ្ញើ អំបុក ចុះខ្ញុំនៅព្រៃនេះ គេនៅភូមិ គេមករកស៊ី។ កន្លែងព្រៃមាន់ខាងជើង គេរកស៊ី ចេញចូលជំបូងអ្នករត់ពន្ធចេញចូលម្តុំព្រៃមាន់នឹងរកស៊ី។ ខ្ញុំចេញកាលនឹងខ្ញុំនៅនឹង នាំកូនចៅមកនៅព្រៃមាន់។

ដាវ៉ា : អ៊ំនៅភ្នំទ្រយោងនឹង អ៊ំមានដែលប្រទះឃើញមានការកាប់សម្លាប់ដែរ នៅភ្នំទ្រយោង?

សឿន : អត់ទេ។ ឃើញគេបញ្ជូនទៅក៏មិនឃើញអីធម្មតា ដូចថានាំទៅធ្វើការងារចឹង មកវិញចូលកន្លែងទៅ។ ហើយអ្នកធ្វើការអត់មានធ្ងន់នឹង ឃើញធ្វើចល័តធ្វើអី នៅធ្វើមានកម្លាំង នៅការពារគាស់ថ្ម គាស់អីកាប់ដីដាំបន្លែ ដាំអី នៅធ្វើបន្លែជាមួយពួកខ្ញុំ។ ខ្ញុំក៏ធ្វើបន្លែធ្វើអីជាមួយគ្នានឹង អត់មានធ្វើអី។

ដានី : ចុះអ៊ំមានប្រសាសន៍ថាគេទៅធ្វើការគាស់ថ្ម គេគាស់ថ្មយកធ្វើអី?

សឿន : ថ្មនឹងដឹកទៅតាមស្ពាន តាមអី។ គាស់ថ្ម វៃហើយបំបែកគេយកមកដឹក យកមកធ្វើស្ពានតាមប្រឡាយ តាមអីនឹង ចាក់ធ្វើស្ពាន ធ្វើផ្លូវទឹក ធ្វើទ្វារទឹកនឹង ដើម្បីវៃឲ្យគេ។ គេមកដឹកយកទៅ ឡានគេមកដឹកយកទៅ យកថ្មនឹងទៅធ្វើស្ពាន។ រួចយកកម្លាំងអស់នឹង ទៅវៃថ្មដើម្បីយកអាថ្មនឹងទៅធ្វើស្ពានយើងទៅវិញណា សម័យនឹងអត់មានកន្លែងវិញទេ។ តែតាមស្រុកមួយៗថ្ងៃ ដូចថាត្រូវការធ្វើទ្វារទឹកណា អានឹងមានកម្លាំងវៃថ្ម គេមកដឹកយកទៅ។ យកធ្វើស្ពាន ចាក់ផ្លូវ ចាក់គ្រឹះអីនឹង។

ដានី : អ៊ំដូចកាលជំនាន់អ៊ំនៅនឹង អ៊ំដែលឃើញគេធ្វើទារុណកម្មធ្វើអី?

សឿន : អត់ឃើញទេ។

ដាវ៉ា : អ្នកជាប់ឃុំនៅសន្តិសុខភ្នំទ្រយោងនឹង នៅជាប់របៀបម៉េច?

សឿន : វាតិចគ្នាដែរ មិនច្រើនទេ។

ដាវ៉ា : ដែលមានដាដាក់ខ្នោះ ដាក់អីដែរ?

សឿន : ដឹងម៉េច កន្លែងគេ បើខ្ញុំមិនសូវចូលទៅដល់កន្លែង នៅក្រៅ។ នៅពេទ្យផ្ទះល្វែងដាច់គ្នាម៉ាល្វែងដាច់គ្នា២០០ម៉ែត្រ ៥០០ម៉ែត្រ។ ប៉ុនថា ព្រលឹមឡើងដេកទៅ យប់ដេកព្រលឹមឡើងយើងគិតការងារ គេហៅទៅធ្វើនេះ នាំឡើងទៅ ដឹងតែធ្វើការងារ។

ដាវ៉ា : ចុះរាល់ថ្ងៃ អ៊ំដឹង យាយ ថែម នៅណាដែរ?

សឿន ៖ ថានៅព្រះវិហារ ។

ដារ៉ា ៖ នៅព្រះវិហារ?

សឿន ៖ បាទ!

ដារ៉ា ៖ យាយ ចែម នៅរស់ទេ ចឹង?

សឿន ៖ នៅ ។

ដារ៉ា ៖ នៅ ។ ដែលជួបគ្នា តាំងពីបែក?

សឿន ៖ អត់ៗដែលជួបទេ ខ្ញុំមិនសូវដើរផង ដែលដើរទៅណា ។

ដានី ៖ ចុះអ៊ីខ្ញុំចង់តតិច អ៊ីមិញកន្លែងថា ឃុំរហាល ឈ្មោះ តា ណុប ចឹង?

សឿន ៖ បាទ!

ដានី ៖ តា ណុប អ្នកស្រុកណាដែរ?

សឿន ៖ តា ណុប អ្នកស្រុក នៅកំពត នៅណាទេ ស្រុកគាត់មិនច្បាស់ ។

ដានី ៖ ប៉ុន្តែ អ៊ីអត់ដឹងថាគាត់នៅណា?

សឿន ៖ បាទ! អត់ដឹងនៅណា ។

ដានី ៖ ចុះឈ្មោះ ហ៊ូវ?

សឿន ៖ ហ៊ូវ ដឹងនៅណា ។

ដានី ៖ ចុះឃុំទៀនកាំ ឈ្មោះអីទៅ?

សឿន ៖ កំពុងនឹកឈ្មោះ(សើច) ។

ដានី ៖ ចុះឃុំព្រះនេត្រព្រះ?

សឿន ៖ ព្រះនេត្រព្រះ ឈ្មោះ ណុញ ។

ដានី ៖ ឈ្មោះ ណុញ?

សឿន ៖ បាទ!

ដានី ៖ គាត់នៅណាដែរ ណុញ ឥឡូវ?

សឿន ៖ ដឹងគាត់នៅណាទេ ឥឡូវ ប៉ុនសួរឮថាស្លាប់ហើយ បាត់សូន្យ បែកគ្នាទៅវា ។

ដានី ៖ គាត់មកពូស្រុកណាដែរ ណុញ?

សឿន ៖ ណុញ គាត់នៅកំពតដែរ ។

ដានី ៖ កំពត?

សឿន ៖ ហ្នឹងហើយ ។

ដានី ៖ ចុះខាងទឹកដោរ?

សឿន : ហ៉េ! ភ្លេចឈ្មោះហើយ ។

ដានី : ភ្លេចហើយអ៊ំ?

សឿន : បាទ!

ដានី : ចុះអ៊ំខាងព្រះនេត្រព្រះ អ៊ំស្គាល់ តា ផន ទេ?

សឿន : ផន គាត់នៅចល័តស្រុក ឃុំនឹងដែរ ។

ដានី : គាត់នៅចល័តឃុំ?

សឿន : បាទ!

ដានី : អ៊ំស្គាល់គាត់ច្បាស់ដែរ?

សឿន : មិនច្បាស់ទេ គាត់នៅចល័ត ។ ចុះចល័តធ្វើការជាមួយគ្នា លើកប្រឡាយលើកអីដូបគ្នា ។

ដានី : តា ផន គាត់អ្នកស្រុកណា?

សឿន : គាត់នៅព្រះនេត្រព្រះនឹងម៉ង ។

ដានី : គាត់នៅព្រះនេត្រព្រះនឹងម៉ង?

សឿន : អឺ! ស្រុកគាត់នៅព្រះនេត្រព្រះ ។

ដានី : សព្វថ្ងៃ គាត់នៅណាដែរ?

សឿន : ដឹងនៅណាទេរាល់ថ្ងៃ បែកគ្នាយូរ មិនសួរស្រាវជ្រាវរកគេណា ឃើញមុខគ្នាក៏ ហឺ!ទៅ ។

ដារ៉ា : ចុះក្រោយមក ពេលអ៊ំមកនៅម្តុំនឹងអី មកនៅនឹងអ៊ំធ្លាប់បានឮឈ្មោះ ផន អីនៅរស់នៅកន្លែងណាទេ?

សឿន : អត់ៗ អត់មានឮដំណឹងអីទេ ។

ដារ៉ា : អត់មានឮដំណឹងទេ?

សឿន : បាទ! អត់មានឮដំណឹង បែកគ្នារហូត ។

ដានី : បែកគ្នារហូត?

សឿន : បាទ! បែកគ្នារហូត(សើច) គេក៏បែកខ្ញុំៗក៏បែកគេ ទាំងអស់គ្នាទៅ ។

ដានី : ចុះកាលនឹងគណៈតំបន់ឈ្មោះអីទៅ កាលអ៊ំមកនៅដំបូង ឃើញនៅតែគណៈតំបន់ឈ្មោះ ជៀល មួយ ។ ដល់ពេល ជៀល ក្រោយមកម៉េចទៀត?

សឿន : ជៀល នឹង ក្រោយមក ស្ងាត់ៗ ឮថាគេដកចេញហើយ ។

ដានី : ហើយគេដាក់ពីណាវិញ?

សឿន : ភ្លេចឈ្មោះពួកនឹង បាត់ឈ្មោះពួកនឹង ភ្លេចឈ្មោះវា ។

ដានី : អ្នកមកពីស្រុកណាដែរ?

សឿន ៖ ពួកនឹង ដឹងស្រុកកំណើតគាត់នៅណា ខ្ញុំអត់សូវដឹងស្រុកកំណើតគាត់ គណៈតំបន់ ឃើញគាត់ដើរធ្វើជាមួយ យាយ ចែម ដើមធ្វើប្រឡាយធ្វើអី ។ ពេលធ្វើប្រឡាយកន្លែងណាគាត់ដើរបង្ហាញកន្លែងធ្វើ ចង្អុរទិសពីនេះទៅនោះ ។ ហើយពេលប្រជុំចល័តឲ្យធ្វើនឹង ឃើញគាត់ ។

ដានី ៖ ឈ្មោះ រិន ហើយមិនមែនទេ?

សឿន ៖ ហ្នឹង ដូច រិន ចឹងហើយ ។

ដានី ៖ ឈ្មោះ រិន?

សឿន ៖ បាទ!

ដានី ៖ គេហៅគាត់ រិនៗចឹង?

សឿន ៖ រិនៗចឹងហើយ គណៈតំបន់ ។

ដានី ៖ រិន នឹង គាត់នៅគណៈតំបន់រហូតដល់យួនចូលដែល ហើយក៏ម៉េចដែរ?

សឿន ៖ ហើយដល់ពេលយួនចូល ស្រាប់បាត់គាត់ អត់ឃើញ ។

ដានី ៖ អត់ឃើញ?

សឿន ៖ ហ្នឹង ដឹងគាត់ទៅណា ។

ដានី ៖ អត់ឃើញទេ កាលនឹង?

សឿន ៖ ហ្នឹងអត់ឃើញ ។

ដានី ៖ តែមានគេដាក់គណៈតំបន់ ជំនួសគាត់ទេ?

សឿន ៖ អត់ ចុះយួនចូលមកហើយ មានគណៈតំបន់ណាទៀត?

ដានី ៖ ក្រែងបាត់គាត់មុនយួនចូល?

សឿន ៖ ដូចបាត់គាត់មុន យួនចូលសម្រាប់តែអត់ឃើញ អត់ដឹងគាត់បាត់ដង ដល់យួនចូលស្រាប់អត់ឃើញគាត់ ។ ដល់យួនចូលស្រាប់អត់ឃើញគាត់ ឃើញនាំគ្នារត់ទៅ អត់មានឃើញគាត់ ។

ដានី ៖ តែអឹអត់មានដឹង គេតែងតាំងគណៈតំបន់អីថ្មី?

សឿន ៖ អត់ៗ ដឹង ហើយពូ រិន នឹងហើយ តែងតាំង ហើយស្គាត់នឹងមក ឃើញយាយ ចែម គាត់គ្រប់គ្រងនៅស្រុក គណៈតំបន់ស្រាប់បាត់ តារិន នឹង ពេលរត់យួន ។ ពេលចលនាបុកមកនឹង អត់ឃើញ ស្រាប់តែបាត់គាត់សូន្យ រត់ចូលមកព្រៃ ធ្លាយដងរែកចឹងទៅ អត់ឃើញគាត់ ។ ធ្លាយដងរែក ក៏អត់មានឃើញ ។

ដារ៉ា ៖ ខ្ញុំបានសួរនាំអ៊ំច្រើនហើយ ។ ហើយដូចជាអស់ចម្ងល់ដែរហើយ ។ ហើយអ៊ំមានអីដែលចង់

ជួយបំភ្លឺពួកខ្ញុំថែមទៀត កន្លែងដែលពួកខ្ញុំអត់ច្បាស់កន្លែងណាអីចឹង អ៊ំ ។

សឿន ៖ ខ្ញុំក៏មិនសូវច្បាស់ដែរ ការងារខ្ញុំ គេឲ្យធ្វើការណា ខ្ញុំធ្វើការងារនឹង កាលណាយើងរំលោភសិទ្ធិទៅ គេថាយើងចេះដឹងការងាររបស់គេ ។ ដូចពេលរត់មកចឹង ខ្ញុំក៏ឈប់ធ្វើអីទាំងអស់ ខ្ញុំគេឲ្យធ្វើចំរូង១ ទៅមុខដឹកជញ្ជូនទៅមុខទៅ ទៅវ៉ៃ ។ ចុះមករស់ជាមួយគេ ខ្ញុំធ្វើដើម្បីការពារកូនចៅខ្ញុំរហូតមកដល់នេះ(សើច) ដើម្បីការពារកូនចៅឲ្យបានសុខរហូតមក កុំឲ្យវាមានបាក់បែកគ្នា គ្រួសារនៅជាប់គ្នារហូតមកមិនដែលបាក់បែកគ្នា ។

ដានី ៖ ចុះអ៊ំខស្សព្រាហ៍ទៅលេងស្រុកកំណើតទេ?

សឿន ៖ ទៅបាន២ដង ខ្ញុំទៅធ្វើខឿន១ពុក ។

ដានី ៖ ទៅបាន២ដង?

សឿន ៖ បាទ! ទៅធ្វើខឿននឹង ម៉ាខែបានមកវិញ ។

ដាវ៉ា ៖ ចុះអ៊ំអត់មានជាប់សាច់ញាតិអីជាមួយតាម៉ុកទេ?

សឿន ៖ អត់ទេ ឆ្ងាយគ្នា ។

ដានី ៖ ឆ្ងាយ?

សឿន ៖ បាទ! គ្រាន់នៅភូមិជាប់គ្នា ។

ដានី ៖ ចុះ តា ទិត?

សឿន ៖ តា ទិត អានឹងសុទ្ធតែខ្សែរបស់គាត់ ។

ដានី ៖ តែអ៊ំអត់មានជាប់សាច់ញាតិអីជាមួយគាត់ទេ?

សឿន ៖ បាទ! អត់ទេ ។ អានឹងខាងខ្សែរបស់គាត់ នៅខាងលិចវត្ត ភូមិជ្រេងគ្នា ខ្ញុំភូមិជ្រេងជាប់គ្នា ប៉ុននៅក្នុងឃុំជាមួយគ្នា ប៉ុនមួយចុងជើង មួយចុងត្បូង ។

ដាវ៉ា ៖ អ៊ំនៅខាងត្បូង?

សឿន ៖ ខ្ញុំនៅចុងត្បូងនោះ ជាប់ជាងទង ជាប់នឹងសំរោង ។

ដានី ៖ ចុះអ៊ំមានដែលទៅព្រះនេត្រព្រះ ក្រោយមកពីបែក៧៩មក?

សឿន ៖ ខ្ញុំទើបនឹងជិះឡានឆ្លងកាត់នឹង ។

ដានី ៖ អ៊ំអត់ចូលលេង នៅព្រះនេត្រព្រះនឹង?

សឿន ៖ ឡានមកក៏កុន(លឿន) ទៅក៏កុន ចុះឡានគេ យើងទៅ ។ ខ្ញុំទៅវិញនេះសៀមរាប ទៅវិញធុងទឹក ។

ដានី ៖ ប៉ុន្តែអ៊ំធ្លាប់ធ្វើជាប្រធានចល័តអីចឹង អ៊ំអត់មានខ្លាចគេខឹងអ៊ំ ហើយក៏ដូចថាគេគុំអ៊ំអី អ៊ំមានអារម្មណ៍ខ្លាចចឹងដែរអត់?

សឿន ៖ ខ្ញុំអត់មានខ្លាចអី ពេលខ្ញុំទៅធ្វើការចល័តនឹង នៅស្រុកគេនឹង ខ្ញុំដើរសព្វដី ដើររកស៊ីដើរអីនឹង ដើរតែឯង១ មិនសូវខ្លាច ។

ដានី ៖ អត់ខ្លាចទេ?

សឿន ៖ បាទ!អត់ខ្លាចទេ ។ ហើយចេញមករហូតចឹង ក៏អត់មានទឹកខ្លាចថាទៅនេះ ខ្លាចគេវ៉ៃអីអត់ ។

ដានី ៖ ម៉េចបានអ៊ំអត់ខ្លាចចឹង?

សឿន ៖ ព្រោះខ្ញុំមិនធ្វើអីគេឲ្យខ្លាំង ចេះធ្វើ១ អ្នកស្រុកនៅនឹងដូចខ្ញុំមិនដែលធ្វើអី ដូចថាចង់បែងចែក កម្លាំងពីនេះ១ទៅ ក៏ខ្ញុំអត់មានបែងចែកកម្លាំង ។

ដានី ៖ អ៊ំបើសិនជាថ្ងៃណាមួយ បើសិនជាថ្ងៃណាមួយអ៊ំត្រូវត្រឡប់ទៅលេងទៅអីខាងភ្នំទ្រយោង ទៅខាងព្រះនេត្រព្រះអី អ៊ំហ៊ានទៅទេ?

សឿន ៖ បាទ! ហ៊ាន ។

ដារ៉ា ៖ ចុះបើអ៊ំអញ្ជើញអ៊ំទៅធ្វើកឋិននៅវត្តព្រះនេត្រព្រះ អ៊ំអញ្ជើញទៅទេ?

សឿន ៖ អត់មានលុយផង ទៅដល់មានលុយមានអីបានស្រួល បើយើងអត់ថវិកា ។

ដានី ៖ បើសិនមានថវិកា ឧបមាថាមានខាងគេឧបត្ថម្ភអ៊ំទៅអី អ៊ំទៅ?

សឿន ៖ ទៅ ។

ដានី ៖ ចុះមួយទៀត បើសិនជាខាងតុលាការគេអញ្ជើញអ៊ំអីទៅចូលរួមសវនាការ អ៊ំអញ្ជើញទៅទេ ទៅភ្នំពេញ?

ដារ៉ា ៖ ទៅស្តាប់ ទៅមើលអ៊ំ?

សឿន ៖ បាទ! ទៅមើលខ្ញុំទៅ ទៅបំភ្លឺគេនឹង បើគេអញ្ជើញបំភ្លឺ ខ្ញុំបំភ្លឺតាមការយល់ដឹងរបស់ខ្ញុំ តាមការរស់នៅរបស់ខ្ញុំ ។ ខ្ញុំរស់នៅរបស់ខ្ញុំ ខ្ញុំរស់នៅរបៀបណា យើងធ្វើតាមនឹង និយាយតាមនឹង ។

ដារ៉ា ៖ ចុះរាល់ថ្ងៃ អ៊ំធ្លាប់បាន ស្តាប់បានដូចទូរទស្សន៍អី ទាក់ទងនឹងសាលាក្តីខ្មែរក្រហម?

សឿន ៖ បាទ! មើល ។

ដារ៉ា ៖ មើលដែរ?

សឿន ៖ បាទ!

ដារ៉ា ៖ ព្រោះកន្លែងខ្ញុំធ្លាប់អញ្ជើញអ្នកស្រុកអ្នកភូមិ ទៅចូលរួមស្តាប់សវនាការផ្ទាល់តែម្តង ហើយបើសិនជាពួកខ្ញុំអញ្ជើញអ៊ំទៅ អ៊ំអញ្ជើញទៅទេ?

សឿន ៖ ទៅ ។

ដារ៉ា ៖ ទៅ? ព្រោះថ្ងៃ១៩នេះ គេមានសវនាការ ។ ថ្ងៃ១៩ដល់ថ្ងៃ២០ គេមានសវនាការរឿង

សុខភាពរបស់ អៀង ធីរិទ្ធ ។ ចឹងគេផ្សាយបន្តផ្ទាល់ដែរ អ៊ំអាចតាមដានពេលនឹង ។ បើសិនជាអ៊ំអញ្ជើញទៅមែន ពួកខ្ញុំអញ្ជើញទៅ ។ អ៊ំអញ្ជើញទៅដែរ?

សឿន : ជិះឡានមិនសូវបានទៀតខ្ញុំ ។

ដារ៉ា : ចឹង?

សឿន : ហ្នឹង ជិះធ្វើទុក្កម៌ង កូនវិលទៅស្រុកនឹង ទៅដល់ដេកបាន២-៣ថ្ងៃបានងើប ហើយមកវិញដេករហូត ។

ដានី : ដូចថាមានគ្នា ដូចថាខ្ញុំអញ្ជើញដូចថាពូប្រធានភូមិទៅជាមួយអ៊ំៗទៅទេ?

សឿន : អានឹងសួរតាមសុខភាពដែរ ប៉ុនបើជិះឡានធ្វើទុក្ខវិលចុករោយ ធ្វើទុក្ខមែនទែន ។ មិនសូវហ៊ានជិះទៅណា ដោយសារថ្ងៃមុនទៅទិញធុងទឹកនៅសៀមរាបនឹង ទៅដោយបន្ទុំ ខ្លួនឯងឈឺលើសឈាម ។

ដារ៉ា : ចុះអ៊ំពេលដែលជិះកាត់កន្លែងព្រះនេត្រព្រះ អ៊ំនៅចាំកន្លែងទាំងអស់ដែរ?

សឿន : ជិះមកចាំម្តុំៗដែរ ។

ដារ៉ា : មានការខុសប្លែកអីខ្លាំង?

សឿន : វាមើលទៅប្លែក ។ ចុះពីមុន យើងគ្មានស្អី ដល់ឥឡូវផ្ទះសម្បែងគេធ្វើនៅនឹងផ្លូវទៅ ខ្ញុំទៅការផ្លូវធ្វើហើយស្រួល ទើបផ្លូវធ្វើហើយស្រួល ទៅតាមផ្លូវស្រួល ។ មានស្ពាន មានអីតាមរហូតទៅ ។ ហើយអាប្រឡាយខ្ញុំលើកនឹង ក៏មើលលែងចង់ស្គាល់ ចុះវាលើកហឹកហាក់ហើយបាទ! ។

ដានី : អត់មានឈ្មោះទេ ប្រឡាយអ៊ំធ្វើ?

សឿន : អត់មានឈ្មោះ ឥឡូវដឹងគេដាក់ឈ្មោះអី ។

ដារ៉ា : ចឹងពួកខ្ញុំដូចអត់មានចម្ងល់អីផ្សេងទៀតទេ អ៊ំខ្ញុំអរគុណអ៊ំច្រើនដែលបានផ្តល់បទសម្ភាសន៍អ៊ំបាទ!ខ្ញុំអរគុណ ។

សឿន : បាទ! អរគុណប្អូន ដែលបានយកព័ត៌មាន ។

"ចប់"